គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា

Cooperation Committee
for Cambodia

Comité de Coopération
Pour le Cambodge

# ធម្មនុញ្ញ និងលក្ខន្តិកៈ

ធ្វើនៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៨

# ធម្មនុញ្ញ និងលក្ខន្តិកៈ

## មាតិកា

## ១. ធម្មនុញ្ញ


ប្រការ ១ ---------- ៤

១.០_ ឈ្មោះ និងគោលដៅ---------- ៤

ប្រការ ២ ---------- ៥

២.០_ រូបសញ្ញា និងត្រា ---------- ៥

ប្រការ ៣ ---------- ៥

៣.០_ រចនាសម្ព័ន្ធនៃ (គ.ស.ក.) ឬ (C.C.C.) ---------- ៥

ប្រការ ៤ ---------- ៦

៤.០_ សមាជិកភាព/ អង្គប្រជុំ/ ការបោះឆ្នោត ---------- ៦

ប្រការ ៥ ---------- ៧

៥.០_ គណៈកម្មាធិការប្រតិបត្តិ ---------- ៧

ប្រការ ៦ ---------- ៨

៦.០_ គណៈកម្មាធិការនានា ---------- ៨

ប្រការ ៧ ---------- ៨

៧.០_ នាយកប្រតិបត្តិនៃ (គ.ស.ក.) ឬ (C.C.C.) និងការិយាល័យ ---------- ៨

ប្រការ ៨ ---------- ៨

៨.០_ ផ្នែកហិរញ្ញវត្ថុ ---------- ៨

ប្រការ ៩ ---------- ៩

៩.០_ ការធ្វើវិសោធនកម្មធម្មនុញ្ញ ---------- ៩

ប្រការ ១០ ---------- ៩

១០.០_ ការរំលាយ និងការចាត់ចែងទ្រព្យសម្បត្តិនៅពេលដែលត្រូវ
រំលាយអង្គការ ---------- ៩

ប្រការ ១១ ---------- ១០

១១.០_ រចនាសម្ព័ន្ធ និងដំណើរការប្រព្រឹត្តិទៅ
របស់ (គ.ស.ក.) ឬ (C.C.C.) ---------- ១០

## ២. លក្ខន្តិកៈ


**ប្រការ ១: ឈ្មោះ និងគោលដៅ** -------------------------------- **១១**

១.១.ឈ្មោះ និងគោលដៅ -------------------------------- ១១

**ប្រការ ២: ទីស្នាក់ការ** -------------------------------- **១១**

**ប្រការ ៣: រចនាសម្ព័ន្ធ** -------------------------------- **១១**

៣.១. រចនាសម្ព័ន្ធនៃ (គ.ស.ក.) ឬ (C.C.C.) ---------------- ១១

៣.២. លក្ខណៈចូលរួមក្នុង (គ.ស.ក.) ឬ (C.C.C.) ------------- ១២

៣.៣. ករណីធ្វើវិសោធនកម្មជាបន្ទាន់ ---------------------- ១២

៣.៤. ការធ្វើវិសោធនកម្មលក្ខន្តិកៈ ------------------------ ១២

**ប្រការ ៤: សមាជិកភាព** -------------------------------- **១៣**

៤.១ ប្រភេទនានានៃសមាជិកភាព ---------------------- ១៣

៤.២. លក្ខណៈសមស្របនៃសមាជិកភាព -------------------- ១៣

៤.៣. បែបបទដាក់ពាក្យសុំចូលជាសមាជិក ------------------- ១៤

៤.៤. ការបញ្ឈប់សមាជិកភាព ---------------------------- ១៦

៤.៥. អំពីអង្គប្រជុំ ------------------------------------ ១៧

៤.៦. ចំនួនសមាជិកចាំបាច់ដើម្បីដំណើរការអង្គប្រជុំបាន (Quorum) - ១៧

៤.៧. អំពីការផ្ទេរសិទ្ធិ ---------------------------------- ១៧

៤.៨. អំពីការបោះឆ្នោត --------------------------------- ១៨

**ប្រការ ៥: គណៈកម្មាធិការប្រតិបត្តិ** ------------------------ **១៩**

៥.១. តួនាទីនៃគណៈកម្មាធិការប្រតិបត្តិ ---------------------- ១៩

៥.២. ភារកិច្ចនានានៃគណៈកម្មាធិការប្រតិបត្តិ ----------------- ២០

៥.៣. កាតព្វកិច្ចរបស់សមាជិកនៃគណៈកម្មាធិការប្រតិបត្តិ --------- ២១

៥.៤. នីតិវិធីនៃការបោះឆ្នោតសំរាប់គណៈកម្មាធិការប្រតិបត្តិ-------- ២១
៥.៥. បែបបទការងារ ------------------------------ ២២
៥.៦. កំណត់ហេតុអង្គប្រជុំ និងវត្តមាន --------------------- ២៣
៥.៧. ការរំសាយគណៈកម្មាធិការប្រតិបត្តិ -------------------- ២៣
**ប្រការ ៦: គណៈកម្មាធិការនានា -------------------------------២៤**
៦.១.ការតែងតាំងគណៈកម្មាធិការនានា(ក្រៅពីគណៈកម្មាធិការប្រតិបត្តិ)២៤
៦.២. សិទ្ធិចូលរួមក្នុងគណៈកម្មាធិការនានា -------------------២៤
៦.៣. បែបបទអនុវត្តការងាររបស់គណៈកម្មាធិការ ---------------២៥
**ប្រការ ៧: នាយកប្រតិបត្តិ -------------------------------------២៥**
៧.១. អណត្តិ តួនាទី និងភារកិច្ចរបស់នាយកប្រតិបត្តិ--------------២៥
**ប្រការ ៨: ហិរញ្ញវត្ថុ ------------------------------------------- ២៧**
៨.១. គម្រោងថវិកា ----------------------------------- ២៧
៨.២. ចំណាយក្រៅគម្រោងនានា-------------------------- ២៧
៨.៣. កម្រៃសមាជិកភាព ------------------------------- ២៨
៨.៤. ការរៃអង្គាសថវិកា ------------------------------- ២៨
៨.៥. អំណោយបានមកពីអង្គការដែលពុំមែនជាសមាជិក ---------- ២៨
៨.៦. របាយការណ៍ហិរញ្ញវត្ថុនានា------------------------- ២៨
៨.៧. ការចុះពិនិត្យបញ្ជីហិរញ្ញវត្ថុ------------------------- ២៨

# ធម្មនុញ្ញ
# នៃ
# អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

## សេចក្តីផ្តើម:

ចាប់តាំងពីឆ្នាំ ១៩៧៩ មកអង្គការក្រៅរដ្ឋាភិបាលដែលអនុវត្តការងារដោយពុំយកផលចំណេញ បានធ្វើសកម្មភាពបំរើប្រជាពលរដ្ឋកម្ពុជាក្នុងវិស័យមនុស្សធម៌ ការអភិវឌ្ឍរួមជាមួយនឹងការផ្តល់ជំនាញបច្ចេកទេស និងធនធានផងដែរ។ ដោយចំនួនអង្គការទាំងនេះ បានកើនឡើងយ៉ាងច្រើន ជាហេតុបណ្តាលអោយមានការបង្កើតជា អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា **(គ.ស.ក)** ឬជាភាសាអង់គ្លេសថា (**C.C.C.**) នេះឡើង។ **(គ.ស.ក.)** ឬ (**C.C.C.**)គឺជាវេទិកាដ៏សមស្របមួយដើម្បីសម្របសម្រួលការផ្តល់ជំនួយបច្ចេកទេស និងមនុស្សធម៌ដល់ប្រជាពលរដ្ឋកម្ពុជា។

## ប្រការ ១:

### ១.០. ឈ្មោះ និងគោលដៅ

១.១. តទៅអង្គការនេះនឹងត្រូវទទួលស្គាល់ថា (អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា) ហើយជាបន្តបន្ទាប់គឺហៅកាត់ថា **(គ.ស.ក.)** ឬ (**C.C.C.**)។

១.២. គោលដៅនៃ **(គ.ស.ក.)** ឬ (**C.C.C.**) គឺមានចែងដូចខាងក្រោមនេះ÷

១.២.១. សម្របសម្រួលការប្រាស្រ័យទាក់ទង និងការផ្លាស់ប្តូរព័ត៌មានទាំងឡាយរវាងអង្គការ NGOs នានា ដែលមានសកម្មភាពនៅកម្ពុជា ក្នុងគោលបំណងពង្រឹងការចូលរួមចំណែក និងការសហប្រតិបត្តិការលើសកម្មភាពនានារបស់ NGOs ដោយជៀសវាងការធ្វើការងារជាន់គ្នា (ឧ. អង្គការទីទៃពីគ្នា ប៉ុន្តែធ្វើការងារដូចគ្នា)។

១.២.២. ផ្តល់វេទិកាមួយសំរាប់ NGOs ដើម្បីសម្របសម្រួលបញ្ហានានាដែលជាផលប្រយោជន៏រួម ក្នុងគោលបំណងសំរួលសំឡេងរួមមួយនៃ NGOs ជាមួយនឹងស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលផ្សេងៗទៀត អង្គការអន្តរជាតិ និងភាគីទាំងឡាយណាដែលមានឥទ្ធិពលខ្លាំង។

<u>ប្រការ ២៖</u>

## ២.០. រូបសញ្ញា និងត្រា

២.១. អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (**គ.ស.ក.**) ឬ (**C.C.C.**) មានរូបសញ្ញាសំគាល់ដូចខាងក្រោម៖

គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee
for Cambodia
Comité de Coopération
Pour le Cambodge

២.២. ត្រារបស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (**គ.ស.ក.**) ឬ (**C.C.C.**) ជាត្រារាងមូលទំហំ៣៤ម.ម. ប្រើទឹកលក្ខ័ពណ៌ខៀវ ។ ត្រាមូលនេះមានរង្វង់មូលមួយនៅផ្នែកខាងក្រៅ និងនៅផ្នែកខាងក្នុងមានរង្វង់មូលមួយ ហើយនៅចន្លោះរង្វង់ទាំងពីរមានអក្សរ " អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា " នៅពាក់កណ្តាលរង្វង់មូល និងមានអក្សរអង់គ្លេស "Cooperation Committee for Cambodia" នៅពាក់កណ្តាលរង្វង់មូលផ្នែកខាងក្រោម ។ នៅក្នុងរង្វង់មូលផ្នែកខាងក្នុងមានប្រអប់បួនជ្រុងបញ្ឈរចំនួនបី ហើយមានអក្សរនៅក្នុងប្រអប់៖

<u>ប្រការ ៣៖</u>

## ៣.០. រចនាសម្ព័ន្ធនៃ(គ.ស.ក.) ឬ(C.C.C.)

៣.១. **គ.ស.ក.** ឬ **C.C.C.** គឺបែងចែកជា០៤ អង្គភាព៖ សមាជិកភាព គណៈកម្មាធិការប្រតិបត្តិ គណៈកម្មាធិការផ្សេងៗ និងនាយកប្រតិបត្តិ បុគ្គលិក និងការិយាល័យដូចចែងក្នុងប្រការ៣,៤,៥, ៦ និងប្រការ៧ នៃធម្មនុញ្ញ (Charter) និងមានចែងបន្ថែមនៅក្នុងលក្ខន្តិកៈ (by-laws) ។

៣.២. **គ.ស.ក.** ឬ **C.C.C.** នឹងព្យាយាមធ្វើឱ្យការចូលរួមដ៏ទូលំទូលាយបំផុតពីសំណាក់ NGOs នានានៅកម្ពុជា។ **គ.ស.ក.** ឬ **C.C.C.** មានគោលជំហរច្បាស់លាស់ក្នុងការជំរុញឱ្យមានការចូលរួម និងវត្តមានសកម្មភាពឱ្យបានច្រើនពីសំណាក់ NGOs ទាំងនោះ។

៣.៣. **គ.ស.ក.** ឬ **C.C.C.** នឹងធ្វើវិសោធនកម្មធម្មនុញ្ញទៅតាមសភាពការណ៍សមស្របនៃការអនុវត្តការងារជាបន្តបន្ទាប់នៃអង្គការដូចចែងក្នុងប្រការ៣ នៃលក្ខន្តិកៈ ។

## ប្រការ ៤:

### ៤.០. សមាជិកភាព/អង្គប្រជុំ/ការបោះឆ្នោត

៤.១. សមាជិកភាពនៃ **គ.ស.ក.** ឬ C.C.C. គឺបើកចំហចំពោះអង្គការនានា ដែលប្រកាន់គោលដៅចំបងលើកស្ទួយការអភិវឌ្ឍ និងការឧបត្ថម្ភផ្នែកមនុស្សធម៌ដោយពុំផ្តោតខ្លាំងលើការផ្សព្វផ្សាយអំពីនយោបាយឬសាសនា។ លក្ខណៈ ប្រភេទ និងបែបបទសមាជិកភាពគឺមានចែងក្នុងប្រការ៤ នៃលក្ខន្តិកៈ។

៤.២. សិទ្ធិ និងភារកិច្ចនៃសមាជិកភាព

៤.២.១. ដោយយោងតាមតួនាទីនៃ **គ.ស.ក.** ឬ C.C.C. ដែលជាអង្គការសំរួលការសំរេចគោលដៅនៃសមាជិកភាពអង្គការសមាជិកភាពរក្សាសិទ្ធិស្វ័យភាព និងការទទួលខុសត្រូវលើកម្មវិធី និងសកម្មភាពរៀង១ខ្លួន។

៤.២.២. ជាការធម្មតាសិទ្ធិសំរេចលើគោលការណ៍ដែលពាក់ពន្ធ័នឹងសមាជិកភាពទាំងមូល គឺជាបន្ទុករបស់សមាជិកពេញសិទ្ធិ។

៤.២.៣. អង្គការដែលជាសមាជិកមានសម្លេងបោះឆ្នោត មួយសម្លេងក្នុងការបោះឆ្នោតតែងតាំងសមាសភាពនានានៃគណៈកម្មាធិការ ហើយបញ្ហានីមួយ១ត្រូវឆ្លងការប្រជុំដែលមានចំនួនចាំបាច់ដើម្បីបើកអង្គប្រជុំបាន (Quorum)។

៤.២.៤. បុគ្គលិកនៃសមាជិក សមាជិកចូលរួម និងសមាជិកពេញសិទ្ធិអាចឈរឈ្មោះបោះឆ្នោតជ្រើសតាំងក្នុងគណៈកម្មាធិការផ្សេង១នៃ **គ.ស.ក.** ឬ C.C.C. ដូចចែងក្នុងប្រការ៤ នៃលក្ខន្តិកៈ។

៤.២.៥. សមាជិកពេញសិទ្ធិ និងសមាជិកចូលរួមមានសិទ្ធិចូលរួមជាអ្នកសង្កេតការណ៍ក្នុងគ្រប់អង្គប្រជុំនៃ **គ.ស.ក.** ឬ C.C.C. លើកលែងតែអង្គប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ។

៤.២.៦. សមាជិកពេញសិទ្ធិ និងសមាជិកចូលរួមមានសិទ្ធិលើកបញ្ហា ពិភាក្សា និងផ្តល់មតិណែនាំលើរាល់ករណីដែលពាក់ពន្ធ័នឹងសកម្មភាព និងដំណើរការនៃ **គ.ស.ក.** ឬ C.C.C.។

៤.២.៧. សមាជិកពេញសិទ្ធិ និងសមាជិកចូលរួមអាចពិនិត្យឯកសារគ្រប់ប្រភេទដែលរក្សាទុកនៅការិយាល័យ **គ.ស.ក.** ឬ C.C.C.។

៤.២.៨.កំរៃសមាជិកភាពគឺត្រូវកំណត់ដោយផ្អែកលើគំរោងថវិកានៃ **គ.ស.ក.** ឬ C.C.C. ដែលបានអនុម័តរួចហើយសមស្របនឹងគោលការណ៍ហិរញ្ញវត្ថុដែលចែងក្នុងប្រការ៨ នៃលក្ខន្តិកៈ។

៤.៣. សមាជិកភាពនឹងអាចបញ្ចប់បានដូចករណីចែងក្នុងប្រការ៤ នៃលក្ខន្តិកៈ។

### ៤.៤. អង្គប្រជុំ និងការបោះឆ្នោត

៤.៤.១. គណៈកម្មាធិការប្រតិបត្តិត្រូវកោះប្រជុំសមាជិកភាពក្នុងមួយខែមួយដង ។

៤.៤.២. រៀងរាល់ឆ្នាំ អង្គប្រជុំប្រចាំខែធ្នូ គឺអង្គប្រជុំប្រចាំឆ្នាំ ដើម្បីបូកសរុបការងារប្រចាំឆ្នាំដែលបានធ្វើកន្លងមក ហើយក៏សំរាប់ពិភាក្សាអំពីផែនការនានាសំរាប់ឆ្នាំបន្ទាប់ផងដែរ ។

៤.៤.៣. អង្គប្រជុំពិសេសដែលរួមមានតំណាងនៃសមាជិកភាព អង្គការនានា និងភ្ញៀវ (ដែលត្រូវបានអញ្ជើញមកចូលរួម) អាចធ្វើទៅបានតាមគោលការណ៍ដូចចែងក្នុងលក្ខន្តិកៈ ។

៤.៤.៤. តំណាងនៃសមាជិកភាពនីមួយៗ មានសិទ្ធិបញ្ចេញមតិដោយបោះឆ្នោតជូនអង្គការដែលខ្លួនតំណាងឱ្យ ។

៤.៤.៥. បែបបទបោះឆ្នោតដើម្បីជ្រើសរើសក្តី ដើម្បីអនុមត័សេចក្តីសំរេចក្តី គឺមានចែងនៅក្នុងប្រការ៤ និង ៥ នៃលក្ខន្តិកៈ ។

## មាត្រា ៥:

### ៥.០. គណៈកម្មាធិការប្រតិបត្តិ

៥.១. អង្គការសមាជិកភាពនៃ **គ.ស.ក.** ឬ **C.C.C.** ត្រូវបោះឆ្នោតជ្រើសរើសសមាជិកចំនួន ០៧ (ប្រាំពីរ)រូប ដើម្បីបង្កើតជាគណៈកម្មាធិការប្រតិបត្តិដែលមានអាណត្តិ ០២ឆ្នាំ។ បន្ទាប់មក គណៈកម្មាធិការប្រតិបត្តិ ត្រូវធ្វើការបោះឆ្នោតតែងតាំងប្រធាន អនុប្រធាន ហេរញ្ញិក និង សមាជិក នៅក្នុងការប្រជុំលើកដំបូងរបស់ខ្លួន។ នាយកប្រតិបត្តិ មានសិទ្ធិចូលរួមតែគ្មានសិទ្ធិសម្រេច (Ex-official) និងជាសមាជិកនៃគណៈកម្មាធិការប្រតិបត្តិដែលគ្មានសិទ្ធិបោះឆ្នោត ។

៥.២. ការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិ ត្រូវធ្វើឡើងម្តងក្នុងមួយឆ្នាំ គឺនៅក្នុងសន្និបាតប្រចាំឆ្នាំដែលត្រូវរៀបចំនៅខែធ្នូជារៀងរាល់ឆ្នាំ។ បែបបទនៃការបោះឆ្នោត មានកំណត់នៅក្នុងប្រការ៤ នៃលក្ខន្តិកៈ ។

៥.៣. ក្នុងករណីសមាជិកគណៈកម្មាធិការប្រតិបត្តិស្នើលាឈប់០២ខែ មុនពេលចប់អាណត្តិ គឺចាំបាច់ត្រូវមានការបោះឆ្នោតរើសសមាជិកជំនួសសំរាប់បន្តអាណត្តិ ។

៥.៤. គណៈកម្មាធិការប្រតិបត្តិ ត្រូវគោរពសេចក្តីសំរេចទាំងឡាយដែលសមាជិកអនុម័ត ។

៥.៥. ភារកិច្ចនៃគណៈកម្មាធិការប្រតិបត្តិ និងសមាជិក (នៃគណៈកម្មាធិការប្រតិបត្តិ) គឺចែងក្នុងប្រការ៥ នៃលក្ខន្តិកៈ ។

៥.៦. បែបបទដំណើរការនៃគណៈកម្មាធិការប្រតិបត្តិគឺចែងក្នុងប្រការ៥ នៃលក្ខន្តិកៈ ។

## ប្រការ ៦៖

### ៦.០. គណៈកម្មាធិការនានា

៦.១. គណៈកម្មាធិការប្រតិបត្តិអាចតែងតាំង និងរំលាយគណៈកម្មាធិការនានា ដើម្បីសំរេចគោលដៅសកម្មភាពនៃ **គ.ស.ក.** ឬ **C.C.C.** ដូចខាងក្រោមនេះ ÷

៦.១.១. អនុគណៈកម្មាធិការតែងតាំងឡើងដើម្បីជាជំនួយការដល់សមាជិកភាព **គ.ស.ក.** ឬ **C.C.C.** ដើម្បី ដោះ ស្រាយបញ្ហាទាំងឡាយដែលជាផលប្រយោជន៍នៃសមាជិកទាំងអស់។

៦.១.២. គណៈកម្មាធិការពិសេសនានា អាចតែងតាំងជាក្រុមការងារ ដើម្បីដោះស្រាយបញ្ហានានា ដែលជាផលប្រយោជន៍សមាជិកភាព **គ.ស.ក.** ឬ **C.C.C.** និងភាគីដទៃទៀត។

## ប្រការ ៧៖

### ៧.០. នាយកប្រតិបត្តិនៃ គ.ស.ក. ឬ C.C.C. និងការិយាល័យ

៧.១. នាយកប្រតិបត្តិ ដោយឆ្លងការប្រឹក្សាយោបល់ជាមួយគណៈកម្មាធិការប្រតិបត្តិ និងសមាជិកភាពទាំងមូល (ដូចចែងក្នុងលក្ខន្តិកៈ មានភារកិច្ចបង្កលក្ខណៈឱ្យមានការិយាល័យ និងបុគ្គលិកស្របតាមសេចក្តីត្រូវការដើម្បីអនុវត្តការងារទាំងឡាយរបស់ **គ.ស.ក.** ឬ **C.C.C.**។ ភារកិច្ច និងលក្ខណៈផ្សេងៗអំពី បុគ្គលិក គឺចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈ)។

## ប្រការ ៨៖

### ៨.០. ផ្នែកហិរញ្ញវត្ថុ

៨.១. គម្រោងថវិការបស់ **គ.ស.ក.** ឬ **C.C.C.** ក៏បានមកពីបង់កម្រៃសមាជិកភាពប្រចាំឆ្នាំ និងតាមរយៈការឧបត្ថម្ភបន្ថែមដែលលើកឡើងដោយអង្គការសមាជិកភាព ឬមកពីប្រភពផ្សេងៗទៀត។

៨.២. គណៈកម្មាធិការប្រតិបត្តិទទួលខុសត្រូវលើការប្រើប្រាស់ថវិកាហើយត្រូវខិតខំគ្រប់គ្រងថវិកា និងអចលនៈវត្ថុរបស់ **គ.ស.ក.** ឬ **C.C.C.** ឱ្យបានសមស្រប។ សមាជិកគណៈកម្មាធិការប្រតិបត្តិជាបុគ្គលក្តី ជាសមូលភាពក្តី ពុំប្រឈមមុខដោយផ្ទាល់នូវភារទ្ធហិរញ្ញវត្ថុផ្ទាល់ខ្លួនណាដែលអាចមានឡើងដោយសារការជាប់ជំពាក់នានាដែលកើតមានឡើងដោយការពាក់ពន្ធ័ជាមួយ គ.ស.ក.ឬ **C.C.C.**។ សមាជិកភាព (ពោលគឺអង្គការដែលជាសមាជិក) ដែលជានិយោជកនៃគណៈកម្មាធិការប្រតិបត្តិ គឺមានការទទួលខុសត្រូវចំពោះការជាប់ជំពាក់ ដែលបណ្តាលឡើងដោយ **គ.ស.ក.**

ឬ C.C.C. តាមលក្ខណៈនិងកិរិតស្មើ និងសមាជិកឯទៀតក៏ដូចជាសមាជិកចូលរួមដែរ ។

៨.៣. គំរោងចំណាយថវិកា នៃឆ្នាំបន្ទាប់ត្រូវលើកពិភាក្សារាល់ឆ្នាំ នាពេលអង្គប្រជុំប្រចាំឆ្នាំ ដើម្បីទទួលបានការគាំទ្រ (ឱ្យសច្ចាប័ន) ពីសមាជិក ។

៨.៤. ទម្រង់ហិរញ្ញវត្ថុ គឺចែងក្នុងប្រការ៧ នៃលក្ខន្តិកៈ) ។

## ប្រការ ៩:

### ៩.០. ការធ្វើវិសោធនកម្មធម្មនុញ្ញ:

៩.១. រាល់ការស្នើកែប្រែលក្ខន្តិកៈត្រូវលើកជូនសមាជិកភាពតាមរយៈគណៈកម្មាធិការប្រតិបត្តិដោយវិធីណាមួយដូចខាងក្រោមនេះ ÷

**ក.** គណៈកម្មាធិការប្រតិបត្តិ លើកសំណើ

**ខ.** អនុគណៈកម្មាធិការកែប្រែលក្ខន្តិកៈ ឬគោលការណ៍ការងារ លើកសំណើរឬ

**គ.** គណៈកម្មាធិការនានា

**ឃ.** ការទទួលឯកសារអំពីការស្នើសុំកែប្រែដែលមានសំលេង ១០% នៃសមាជិកភាពសរុប ហើយដែលបញ្ជាក់ដោយការចុះហត្ថលេខាគាំទ្រភ្ជាប់ជាមួយ ។

៩.២. រាល់ការស្នើសុំកែប្រែលក្ខន្តិកៈ ត្រូវដាក់ជូនគណៈកម្មាធិការប្រតិបត្តិ យ៉ាងហោចណាស់ ១៥ថ្ងៃ មុនការប្រជុំប្រចាំខែជូនសមាជិកភាពដើម្បីពិនិត្យ និងចែកចាយ ។

៩.៣. សំណើកែប្រែទាំងនោះ និងត្រូវលើកមកពិភាក្សាក្នុងអង្គប្រជុំប្រចាំខែ ហើយការវិភាគអំពីការកែប្រែនេះព្រមជាមួយការបោះឆ្នោតអនុមតិការកែប្រែនេះ គឺធ្វើឡើងក្នុងអង្គប្រជុំនៃខែបន្ទាប់ ។

៩.៤. ធម្មនុញ្ញអាចធ្វើវិសោធនកម្មបានលុះត្រាណាតែមានការគាំទ្រសំណើរឱ្យធ្វើការកែប្រែនេះ ដោយមានសម្លេង ២/៣ (៦៧%) នៃអង្គការសមាជិកភាពទាំងអស់ ។

## ប្រការ ១០:

### ១០.០. ការរំលាយ និងការចាត់ចែងទ្រព្យសម្បត្តិនៅពេលដែលត្រូវរំលាយអង្គការ:

១០.១.១. អង្គការគណៈកម្មាធិកាសហប្រតិបត្តិការដើម្បីកម្ពុជា **(គ.ស.ក)** ឬ (C.C.C.) នឹងអាចរំលាយបានលុះត្រាតែមានសំលេងគាំទ្រចំនួន ២/៣ (៦៧%) នៃអង្គការសមាជិកភាពទាំងអស់របស់ខ្លួនតាមរយៈការបោះឆ្នោត ។

១០.២. គណៈកម្មាធិការប្រតិបត្តិនៃអង្គការគណៈកម្មាធិកាសហប្រតិបត្តិការដើម្បីកម្ពុជា (**គ.ស.ក**) ឬ (C.C.C.) ដោយមានកិច្ចសហការពីនាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ និងប្រធានកម្មវិធី នឹងធ្វើរតួនាទីចាត់ចែងការសំអាតបញ្ជីពាក់ពន្ធ័នានា ការទូទាត់សំណងនានា និងការប្រគល់ទ្រព្យសម្បត្តិ ដូចមាននៅក្នុងបញ្ជីសារពើភ័ណ្ឌ (Asset/Inventory List) របស់អង្គការឱ្យទៅម្ចាស់ជំនួយវិញ ឬក៏ប្រគល់ឱ្យទៅអង្គការផ្សេងទៀត ដោយមានការព្រមព្រៀង ពីម្ចាស់ជំនួយជាលាយលក្ខ័អក្សរ ។

## ប្រការ ១១:

### ១០.០. រចនាសម្ព័ន្ធ និងដំណើរការប្រព្រឹត្តិទៅរបស់ (គ.ស.ក) ឬ (C.C.C.)

១១.១. រចនាសម្ព័ន្ធ និងដំណើរការប្រព្រឹត្តិទៅរបស់អង្គការគណៈកម្មាធិកាសហប្រតិបត្តិការដើម្បីកម្ពុជា (**គ.ស.ក**) ឬ (**C.C.C.**) មានកំណត់នៅក្នុងលក្ខន្តិកៈនៅផ្នែក/ទំព័របន្ទាប់ដូចខាងក្រោម:

# លក្ខន្តិកៈ

# របស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

## ប្រការ ១: ឈ្មោះ និងគោលដៅ

### ១.១. ឈ្មោះ និងគោលដៅ

១.១.១.តទៅអង្គការនេះនឹងត្រូវទទួលស្គាល់ថា (**អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា**) ហើយជាបន្តបន្ទាប់គឺហៅកាត់ថា (**គ.ស.ក.**) ឬ (**C.C.C.**)។

១.១.២.គោលដៅនៃ (**គ.ស.ក.**) ឬ (**C.C.C.**) គឺមានចែងដូចខាងក្រោមនេះ÷

១.១.២.១ សម្របសម្រួលការប្រាស្រ័យទាក់ទង និងការផ្លាស់ប្តូរព័ត៌មានទាំងឡាយរវាងអង្គការ NGOs នានា ដែលមានសកម្មភាពនៅកម្ពុជា ក្នុងគោលបំណងពង្រឹងការចូលរួមចំណែក និងការសហប្រតិបត្តិការលើសកម្មភាពនានារបស់ NGOs ដោយជៀសវាងការធ្វើការងារជាន់គ្នា (ឧ. អង្គការទីទៃពីគ្នា ប៉ុន្តែធ្វើការងារដូចគ្នា)។

១.១.២.២ ផ្តល់វេទិកាមួយសំរាប់ NGOs នានា ដើម្បីសម្របសម្រួលបញ្ហាទាំងឡាយដែលជាផលប្រយោជន៍រួម ក្នុងគោលបំណងសំរួលសំឡេងរួមមួយនៃ NGOs ជាមួយស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលផ្សេងៗទៀត អង្គការអន្តរជាតិ និងភាគីទាំងឡាយណាដែលមានឥទ្ធិពលខ្លាំង។

## ប្រការ ២: ទីស្នាក់ការ( ការិយាល័យ) :

២.១. អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (**គ.ស.ក.**) ឬ (**C.C.C.**) មានទីស្នាក់ការ: អគារ #៩-១១, ផ្លូវលេខ ៤៧៦, សង្កាត់ ទូលទំពូង ១, ខណ្ឌ ចំការមន, ប្រអប់សំបុត្រលេខ ៨៩៥, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៣: រចនាសម្ព័ន្ធ

### ៣.១. រចនាសម្ព័ន្ធនៃ គ.ស.ក. ឬ C.C.C.

៣.១.១. **គ.ស.ក.** ឬ **C.C.C.** បែងចែកអង្គភាព ០៤ ជាអាទិ៍មាន: សមាជិកភាព គណៈកម្មាធិការប្រតិបត្តិ គណៈកម្មាធិការនានា បុគ្គលិក និងការិយាល័យ ដូចចែងក្នុងប្រការ ២. ៣. ៤. ៥ . ៦. ៧ និង ៨ នៃលក្ខន្តិកៈ។

## ៣.២. លក្ខណៈចូលរួមនៃ គ.ស.ក. ឬ C.C.C.

២.២.១. **គ.ស.ក.** ឬ C.C.C. នឹងព្យាយាមអញ្ជើញការចូលរួមដ៏ទូលំទូលាយបំផុតពីសំណាក់ NGOs ទាំងឡាយនៅកម្ពុជា។ **គ.ស.ក.** ឬ C.C.C. មានគោលជំហរច្បាស់លាស់ក្នុងការជំរុញឱ្យមានការចូលរួម និងវត្តមានសកម្មភាពឱ្យបានច្រើនពីសំណាក់ NGOs ។

## ៣.៣. ករណីវិសោធនកម្មថវិកាបន្ទាន់

៣.៣.១.ក្នុងករណីបន្ទាន់សេចក្តីសំរេចរំសាយ **គ.ស.ក.** ឬ C.C.C. គឺជាការទទួលខុសត្រូវនៃប្រធានគណៈកម្មាធិការប្រតិបត្តិ និងនាយកប្រតិបត្តិហើយការផ្ទេរឬលក់អចលនៈវត្ថុ គឺអនុវត្តតាមគំរោងការបន្ទាន់ដែលអនុម័តដោយគណៈកម្មាធិការប្រតិបត្តិ ។

## ៣.៤. ការធ្វើវិសោធនកម្មលក្ខន្តិកៈ

៣.៤.១.**គ.ស.ក.** ឬ C.C.C. នឹងអនុវត្តគោលការណ៍ការងារនានាដើម្បីឱ្យដំណើរការការងារអាចធ្វើទៅបានដ៏សមស្របចំពោះអង្គការនេះ ។

៣.៤.២.រាល់សំណើកែប្រែគោលការណ៍ការងារត្រូវឆ្លងកាត់សមាជិកភាពតាមរយៈគណៈកម្មាធិការប្រតិបត្តិ ក្នុងករណីដូចខាងក្រោម ÷

ក. គណៈកម្មាធិការប្រតិបត្តិ លើកសំណើ

ខ. អនុគណៈកម្មាធិការកែប្រែលក្ខន្តិកៈ ឬ គោលការណ៍ការងារលើកសំណើ ឬ

គ. ការទទួលឯកសារអំពីការស្នើសុំកែប្រែដែលមានសំលេង ១០% នៃសមាជិកភាពសរុបហើយដែលបញ្ជាក់ដោយការចុះហត្ថលេខាគាំទ្រភ្ជាប់ជាមួយ ។

៣.៤.៣.រាល់ការស្នើសុំកែប្រែគោលការណ៍ការងារត្រូវដាក់ជូនគណៈកម្មាធិការប្រតិបត្តិ យ៉ាងហោចណាស់ ១៥ ថ្ងៃមុនការប្រជុំប្រចាំខែ ជូនសមាជិកភាពដើម្បីពិនិត្យ និងចែកចាយ ។

៣.៤.៤. សំណើកែប្រែទាំងនេះ នឹងត្រូវលើកមកពិភាក្សាក្នុងអង្គប្រជុំប្រចាំខែហើយការពិភាគអំពីការកែប្រែនេះ ព្រមជាមួយការបោះឆ្នោតអនុម័តការកែប្រែនេះ គឺនឹងធ្វើឡើងក្នុងអង្គប្រជុំនៃខែបន្ទាប់ ។

៣.៤.៥. គោលការណ៍ការងារអាចកែប្រែបានលុះត្រាណាតែមានការគាំទ្រសំណើកំណែនេះ ដោយសម្លេងពីរភាគបី នៃអង្គការសមាជិក ។

# ប្រការ ៤: សមាជិកភាព

## ៤.១. ប្រភេទនានានៃសមាជិកភាព

### ៤.១.១.អង្គការសមាជិក

អង្គការសមាជិកបេក្ខជនដែលមានលក្ខណៈគ្រប់គ្រាន់ដូចចែងក្នុងលក្ខន្តិកៈការងារ ៤.២.១ ដល់ ៤.២.៥ អាចចូលជាសមាជិកពេញសិទ្ធិ។ អង្គការដែលជាអ្នកសង្កេតការណ៍មានសិទ្ធិផ្តល់ មតិ និងបោះឆ្នោត។ និយោជិកនៃអង្គការដែលជាសមាជិកពេញសិទ្ធិអាចឈរឈ្មោះបោះឆ្នោតបំរើក្នុងគណៈកម្មាធិការនានានៃ **គ.ស.ក.** ឬ C.C.C. ។

### ៤.១.២. សមាជិកគាំទ្រ (Associate)

សមាជិកចូលរួមរាល់បេក្ខជន ដែលមានលក្ខណៈគ្រប់គ្រាន់ដូចចែងក្នុងលក្ខន្តិកៈការងារ ៤.២.២ ដល់៤.២.៥ អាចចូលជាសមាជិកចូលរួម។ អង្គការដែលជាសមាជិកចូលរួម គឺមានសិទ្ធិត្រឹមតែផ្តល់មតិប៉ុណ្ណោះ។ និយោជកនៃអង្គការដែលមានលក្ខណៈជាសមាជិកអាចចូលរួមបំរើក្នុងអនុគណៈកម្មាធិការ **គ.ស.ក.** ឬ C.C.C. ឬគណៈកម្មាធិការពិសេស។ អង្គការណាដែលមានលក្ខណៈគ្រប់គ្រាន់ចូលជា សមាជិកពេញសិទ្ធិ ពុំអាចជ្រើសខ្លួនចូលជាសមាជិកចូលរួមបានឡើយ។

## ៤.២. លក្ខណៈសម្រួលនៃសមាជិកភាព

៤.២.១.ត្រូវមានឯកសារបញ្ជាក់ថាជាអង្គការក្រៅរដ្ឋាភិបាល ដែលពុំអាចមានផលចំណេញពីសកម្មភាពរបស់ខ្លួន (Non profit ) (ករណីសមាជិកពេញសិទ្ធិ)។

៤.២.២. គោលដៅចំបង គឺការឧបត្ថម្ភផ្នែកអភិវឌ្ឍន៍ ឬមនុស្សធម៌ពុំផ្តោតលើការលើកស្ទួយនយោបាយ ឬសាសនា។

៤.២.២.១. ក្នុងករណីមានការមន្ទិលសង្ស័យអំពីសកម្មភាពនៃអង្គការណាមួយ **គ.ស.ក.** ឬ C.C.C. រក្សាសិទ្ធិសាកសួរហើយតាមដាន និងស្វែងរកការបញ្ជាក់ (References) នានា។

៤.២.៣. ការិយាល័យជាក់លាក់ សមាជិកត្រូវមានទីតាំងច្បាស់លាស់នៅកម្ពុជាដោយមានតំណាង (Representative) ស្នាក់នៅភ្នំពេញ ឬក៏មានបុគ្គលិកឈរជើងនៅកម្ពុជា ដែលមានសិទ្ធិច្បាស់លាស់ជាតំណាងនៃអង្គការនេះ ហើយដែលមានលទ្ធភាពអាចចូលរួមសកម្មភាពជាមួយ **គ.ស.ក.** ឬ C.C.C. ។

៤.២.៤. កម្មវិធីសមាជិកគឺត្រូវមានកម្មវិធីដំណើរការនៅកម្ពុជា ឬផ្តល់ការឧបត្ថម្ភដល់កម្មវិធីក្តីដល់ NGOs ក្តី ឬការផ្តួចផ្តើមគំនិតក្នុងកម្ពុជា ជាលក្ខណៈបច្ចេកទេសថវិកាក្នុងគោលបំណងឧបត្ថម្ភ

អ្វីដែលជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា។

៤.២.៥. ឯកសារជាក់ស្តែង ត្រូវផ្តល់ដើម្បីបញ្ជាក់ថាករណីខាងលើមានភាពសមស្រប។ ឯកសារចាំបាច់នេះ គឺដូចចែងក្នុងលក្ខន្តិកៈនេះ។

៤.២.៦. ក្រោយពីបានចូលជាសមាជិក **គ.ស.ក.** ឬ **C.C.C.** សមាជិកពេញសិទ្ធិឬសមាជិកចូលរួមចាំបាច់ត្រូវផ្តល់ជា ដំណឹងដល់ **C.C.C** អំពីការផ្លាស់ប្តូរ ឬកែប្រែរចនាសម្ព័ន្ធឬលក្ខណៈរបស់ខ្លួន អង្គការអន្តរជាតិក៏ត្រូវរាយការណ៍ដែរអំពីភាពអ្វីដែលកែប្រែ។ ការជូនដំណឹង គឺត្រូវធ្វើជាលាយលក្ខ័អក្សរ។

៤.២.៧. គណៈកម្មាធិការប្រតិបត្តិ ឬសមាជិកនៃគណៈកម្មាធិការនានាមានសិទ្ធិសាកសួរ ឬពិនិត្យលើសមាជិកភាពដោយផ្អែកលើព័ត៌មានផ្តល់ដោយសាមីអង្គការ ឬដោយផ្អែកលើព័ត៌មានដទៃដែលខ្លួនក្តាប់បាន។

## ៤.៣. បែបបទដាក់ពាក្យសុំចូលជាសមាជិក

៤.៣.១. អង្គការណាដែលមានលក្ខណៈសមស្រប អាចសុំចូលជាអ្នកសង្កេតការណ៍ រយៈពេល ២ ខែ។

៤.៣.២. ក្នុងរយៈពេល២ខែ ជាអ្នកសង្កេតការណ៍អង្គការត្រូវរៀបចំឯកសារសមស្រប ដើម្បីសុំចូលជាសមាជិកពេញសិទ្ធិ ហើយឆ្លងកាត់ការបោះឆ្នោតអនុម័តទទួលស្គាល់ជាសមាជិកពេញសិទ្ធិនៅបំណាច់អាណត្តិជាអ្នកសង្កេតការណ៍នេះ។

៤.៣.៣. ឯកសារ **គ.ស.ក.** ឬ **C.C.C.** មួយសំណុំនឹងត្រូវទទួលបានពីការិយាល័យដែលមានរាយដូចខាងក្រោមនេះ ÷

- ពាក្យស្នើសុំចូលជាសមាជិក
- លក្ខន្តិកៈ និង គោលការណ៍ការងារនៃ **គ.ស.ក.** ឬ **C.C.C.**
- បញ្ជីរាយឈ្មោះអង្គការដែលជាសមាជិកបច្ចុប្បន្ន
- ព័ត៌មានលំអិតអំពីកម្រៃនៃសមាជិកភាព។

៤.៣.៤. ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំចូលជាសមាជិកចូលរួមមាន ÷

៣.៣.៤.១. លិខិត ១ច្បាប់ បញ្ជាក់អំពីគោលបំណងចូលជាសមាជិក **គ.ស.ក.** ឬ **C.C.C.** ជូនដល់នាយកប្រតិបត្តិ **គ.ស.ក.** ឬ **C.C.C.**

៣.៣.៤.២. ពាក្យស្នើសុំចូលសមាជិកភាពត្រូវមាន ÷

១. ឈ្មោះអង្គការ

២. ឈ្មោះតំណាងចាត់តាំង ឬអ្នកតែងតាំងជំនួសដើម្បីចូលរួមប្រជុំនៅ **គ.ស.ក.** ឬ **C.C.C.**

៣. សេចក្តីបញ្ជាក់ ដើម្បីចុះហត្ថលេខាយល់ព្រមគោរពតាមការណី និងលក្ខន្តិកៈ**គ.ស.ក.** ឬ **C.C.C.**

៤. សេចក្តីបញ្ជាក់ដើម្បីចុះហត្ថលេខាអះអាងថា នឹងចូលរួមជាប្រាកដដោយវត្តមានក្តីដោយផ្ទេរសិទ្ធិក្តី (Proxy) ក្នុងអង្គប្រជុំវិសាមញ្ញនៃ **គ.ស.ក.** ឬ **C.C.C.** ។

៥. សេចក្តីបញ្ជាក់ថាអង្គការសាមីនឹងបង់ប្រាក់កំរៃសមាជិកភាពនៅពេលចូល ជាសមាជិក **គ.ស.ក.** ឬ **C.C.C.** ។

៦. ឯកសារផ្លូវការដែលបញ្ជាក់អំពីលក្ខណៈជាអង្គការក្រៅរដ្ឋាភិបាលដែលពុំមានផលចំណេញ (ចេញដោយស្ថាក់ការក្នុងប្រទេស ដែលសាមីអង្គការចុះចូលបញ្ជីជាផ្លូវការ) (ករណីនេះគឺសំដៅចំពោះសមាជិកភាពពេញសិទ្ធិ ) ។

៧. ការពិពណ៍នាអំពីអង្គការរួមមានទស្សនៈ ទិសដៅ ប្រភពថវិកា លក្ខណៈ និងឯកសារផ្តល់ព័តិមានដែលអង្គការប្រើប្រាស់សំរាប់ការរៃអង្គាសថវិកាតាមរយៈស្នាក់ការកណ្តាល ។

៨. ការអធិប្បាយអំពីកម្មវិធីសាមីអង្គការនៅកម្ពុជាដោយបញ្ជាក់អំពីគោលដៅអ្នកទទួលសេវាកម្ម និងគម្រោងថវិកាប្រចាំឆ្នាំ។

៤.៣.៥. ទម្រង់បេក្ខភាព

១. នៅពេលទទួលឯកសារដំបូងស្នើសុំចូលជាសមាជិក នាយកប្រតិបត្តិនឹងជូនដំណឹងដល់គណៈកម្មាធិការប្រតិបត្តិ និងសមាជិកទូទៅអំពីភាពសមស្របនៃអង្គការនោះក្នុងការចូលជាសមាជិកភាព។

២. ក្រោយពេលទទួលបានឯកសារចាំបាច់គ្រាប់គ្រាន់ហើយ គណៈកម្មាធិការប្រតិបត្តិវាយតម្លៃលើសំណើសុំរបស់សមាជិកអង្កេតការណ៍ និងផ្តល់អនុសាសន៍ ថាគួរអញ្ជើញអង្គការអង្កេតការណ៍នោះដាក់ឱ្យគេបោះឆ្នោត ឬឱ្យអង្គការនោះដាក់ជូនបន្ថែមនូវឯកសារចំបាច់ទៀតដើម្បីបញ្ជាក់បន្ថែមពីអង្គការនោះ។

៣. នៅចុងបញ្ចប់នៃដំណាក់កាលអង្កេតការណ៍ គណៈកម្មាធិការប្រតិបត្តិ នឹងបោះឆ្នោតសម្រេចទទួល ឬជិទាស់មិនទទួលឱ្យចូលជាសមាជិកថ្មីដោយសម្លេងភាគច្រើន ៥០%+១។

៤. បើសិនជាទំទាស់ គណៈកម្មាធិការប្រតិបត្តិធ្វើការកត់ត្រាលើលក្ខណៈវិនិច្ឆ័យជាក់លាក់ណាខ្លះសំរាប់ចូលជាសមាជិកដែលអង្គការនោះមិនបានឆ្លើយតបនៅឡើយ។

៥. បន្ទាប់មក នាយប្រតិបត្តិនឹងជូនព័តិមានអំពីលទ្ធផលនៃការបោះឆ្នោតដល់សមាជិក។ សេចក្តីសម្រេចចុងក្រោយជាមួយនឹងគោលបំណងសមហេតុផលនឹងត្រូវកត់ត្រានៅក្នុងកំណត់ហេតុប្រជុំទូទៅរបស់ CCC ។

៦. ការបង់ថ្លៃសមាជិកភាពប្រចាំថ្ងៃនឹងតម្រូវឱ្យទាំងសមាជិកពេញសិទ្ធិ និងសមាជិកទាំងគាំទ្រ ធ្វើឡើងនៅពេលដែលអង្គការនោះបានទទួលការសម្រេចឱ្យចូលជាសមាជិក **គ.ស.ក.** ឬ C.C.C. ។

៧. សមាជិកអង្កេតការណ៍នឹងតម្រូវឱ្យបង់ថ្លៃនូវចំនួនកំណត់មួយជាក់លាក់សំរាប់គ្រប់ដណ្តប់លើសេវាកម្មព័ត៌មាន និងសំភារៈផ្សេងៗដែលបានផ្តល់ជូននៅអំឡុងពេលជាសមាជិកអង្កេតការណ៍។

## ៤.៤. ការបញ្ឈប់សមាជិកភាព

៤.៤.១. សមាជិកភាពនឹងត្រូវបញ្ឈប់ ក្នុងករណីដូចខាងក្រោម ÷

១. ការបោះឆ្នោតដោយសម្លេងភាគច្រើន ៥០%+១ ក្នុងចំណោមសមាជិកភាពបញ្ជាក់ថាសកម្មភាព/គោលដៅ សមាជិកពេញសិទ្ធិ ឬសមាជិកចូលរួមពុំមានលក្ខណៈសមស្រប នឹងគោលដៅ **គ.ស.ក.** ឬ C.C.C. ឬក៏អាចបង្កឱ្យមានផលលំបាកដល់កម្លាំងសមូហភាពនៃសមាជិកភាព **គ.ស.ក.** ឬ C.C.C. ។

២. ការបោះឆ្នោតដោយសម្លេង ៥០%+១ ក្នុងចំណោមសមាជិកភាពអនុម័តថាសាម៉ីអង្គការពុំអាចទទួលបានលក្ខខណ្ឌដូចចែងក្នុងប្រការ៤ និងប្រការបន្តបន្ទាប់នៃលក្ខន្តិកៈ ។

៤.៤.១.១. ក្នុងករណីដែលសមាជិកភាពត្រូវបញ្ឈប់ យោងតាមប្រការ ៣.៤.១ នៃលក្ខន្តិកៈ មូលហេតុដែលស្នើរឡើងដើម្បីបញ្ឈប់សមាជិកភាពដាក់ជូនគណៈកម្មាធិការប្រតិបត្តិយ៉ាងហោចណាស់ ១៥ថ្ងៃ មុនពេលប្រជុំប្រចាំខែ ដើម្បីផ្តល់លទ្ធភាព ពិនិត្យ និងផ្ញើជូន។

៤.៤.១.២. សំណើនេះគឺនឹងលើកយកមកពិភាក្សាក្នុងអង្គការប្រជុំប្រចាំខែ និងត្រូវវ័ឆ្លងកាត់ការបោះ ឆ្នោតនាអង្គប្រជុំប្រចាំខែក្រោយ។

៤.៤.២. ការពុំបង់កំរៃសមាជិភាពប្រចាំឆ្នាំ ផុតកំណត់ ៣ខែ នៃកាលបរិច្ឆេទដែលត្រូវបង់។

៣.៤.២.១. ទាមទារឱ្យមានភស្តុតាងជាក់ស្តែងអំពីការរំលឹកពីរលើកអំពីការបង់កំរៃនេះចំពោះសមាជិកពេញសិទ្ធិ ឬសមាជិកចូលរួមមុននឹងបញ្ឈប់សមាជិកភាព។ ការធ្វើលិខិតរំលឹកនេះគឺជាភារកិច្ចនៃបុគ្គលិករបស់ **គ.ស.ក.** ឬ C.C.C. ។

៣.៤.២.២. ការបញ្ឈប់សមាជិកភាពអនុលោមតាមមាត្រា៣.៤.២ សំរេចឡើងដោយគណៈកម្មាធិការប្រតិបត្តិដោយលិខិតផ្ញើចេញពីការិយាល័យ **គ.ស.ក.** ឬ C.C.C. ។

៤.៤.៣. ការជូនដំណឹងជាលាយលក្ខ័អក្សរអំពីគោលបំណងសមាជិកពេញសិទ្ធិ ឬសមាជិកចូលរួមស្នើដកខ្លួនចេញពីសមាជិកភាព។

៤.៤.៣.១. ក្នុងករណីដែលអង្គការមួយ ដកខ្លួនចេញពីសមាជិកភាពតាមចំនុច ៤.៤.៣ ក្នុងប្រការ៤នៃលក្ខន្តិកៈគណៈកម្មាធិការប្រតិបត្តិមានភារៈកិច្ចជូនជាដំណឹងដល់សមាជិកភាពទាំងមូលនាពេលប្រជុំខែ បន្ទាប់អំពីការស្នើសុំឈប់នេះ។

## ៤.៥. អំពីអង្គប្រជុំ

៤.៥.១. អង្គប្រជុំនឹងត្រូវប្រារព្ធធ្វើយ៉ាងហោចណាស់ពីរខែម្តង កាលបរិច្ឆេទគឺកំណត់ដោយគណៈកម្មាធិការប្រតិបត្តិ ហើយត្រូវជូនជាដំណឹងដល់អង្គការសមាជិក។ តំណាងនៃអង្គការសមាជិកមានសិទ្ធិបញ្ចេញមតិហើយបោះឆ្នោតជូសមុខឱ្យអង្គការដែលខ្លួនតំណាង។ ភ្ញៀវ ឬភាគីដទៃអាចចូលរួមបានលុះត្រាតែមាន ការឯកភាពជាមុនពីប្រធានឬនាយកប្រតិបត្តិ។

៤.៥.២. អង្គប្រជុំពិសេស ដែលរួមមានតំណាង (ឬតំណាងច្រើននាក់) នៃអង្គការសមាជិក និងភ្ញៀវ ឬរួមមានតែតំណាងនៃអង្គការសមាជិក អាចកោះប្រជុំបានតាមរយៈ ÷

៤.៥.២.១. ប្រធានដោយឆ្លងការពិភាក្សាជាមួយសមាជិកឯទៀតនៃគណៈកម្មាធិការប្រតិបត្តិ ឬ

៤.៥.២.២. តំណាងអង្គការសមាជិកស្នើជាលាយល័ក្ខអក្សរដល់ប្រធានហើយដែលគាំទ្រ (ដោយហត្ថលេខា) ដោយសម្លេង ១ភាគ៥ (២០%) ពីសមាជិកទាំងអស់។ អង្គប្រជុំនឹងធ្វើឡើងក្នុងកំឡុង ១០ថ្ងៃបន្ទាប់មក។

## ៤.៦. ចំនួនចាំបាច់ដើម្បីដំណើរការអង្គប្រជុំបាន ( Quorum )

៤.៦.១. រាល់ការប្រជុំដែលកោះហៅពីរសប្តាហ៍ជាមុនត្រូវមានវត្តមានចូលរួមយ៉ាងហោចណាស់ ១/៣ នៃអង្គការសមាជិក។

៤.៦.២. Quorum អាចចាត់ទុកជាគ្រប់តាមរយៈការផ្តល់សិទ្ធិជំនួស (PROXIES)។

៤.៦.៣. ចំនួន Quorum ចាំបាច់ព្រមជាមួយចំនួនអង្គការសមាជិកត្រូវប្រកាសនាពេលចាប់ផ្តើមអង្គប្រជុំនិមួយៗ។

## ៤.៧. ការផ្ទេរសិទ្ធិជំនួស ( PROXIES )

៤.៧.១.ការផ្ទេរសិទ្ធិជំនួសគឺត្រូវធ្វើជាលាយលក្ខ័អក្សរ។ ការណ៏នេះអាចធ្វើបានគឺដោយអង្គការសមាជិកមួយផ្ទេរសិទ្ធិទៅឱ្យសមាជិកពេញសិទ្ធិ ឬសមាជិកគាំទ្រ (Associate)ធ្វើបានបោះឆ្នោតជំនួសខ្លួន។

៤.៧.២. អង្គការសមាជិកអាចបោះឆ្នោត ដោយសម្លេងតាមរយៈការផ្ទេរសិទ្ធិ (PROXIES)។

៤.៧.៣.សមាជិកពេញសិទ្ធិ ឬសមាជិកចូលរួមអាចប្រើសម្លេង Proxy តែមួយដងគត់ក្នុងករណី

និមួយៗ។

## ៤.៨. អំពីការបោះឆ្នោត

៤.៨.១. ប្រធានអង្គប្រជុំទទួលបន្ទុក បង្កលក្ខណៈធ្វើយ៉ាងណាឱ្យសមាជិកចូលរួមប្រជុំ គ្រប់ចំនួនហើយប្រកាសជូនអង្គប្រជុំ។ ជាមួយគ្នាដែរគឺត្រូវពិនិត្យថាសម្លេងផ្ទេរសិទ្ធិទាំងអស់ (All Proxies) គឺត្រឹមត្រូវជាលាយលក្ខ័អក្សរពិតប្រាកដមែនហើយត្រូវធ្វើយ៉ាងណាឱ្យសមាជិកអង្គការបោះឆ្នោតតែមួយសម្លេងក្នុងករណីនិមួយៗ។

៤.៨.២.រាល់ករណីដែលទាមទារការសំរេចតាមសន្លឹកឆ្នោតត្រូវផ្តួចផ្តើមលើកឡើងដោយតំណាងនៃអង្គការ សមាជិកមួយរួចហើយសំណើនេះគាំទ្រដោយតំណាងអង្គការសមាជិកមួយទៀត។

៤.៨.៣.សំណើរទាំងអស់ដែលត្រូវឆ្លងកាត់ការបោះឆ្នោតចាំបាច់ត្រូវកត់ត្រាឱ្យបានច្បាស់លាស់មុននឹងធ្វើការបោះឆ្នោត។

៤.៨.៤. ការបោះឆ្នោតជ្រើសរើសសមាសភាពសមាជិកភាព អំពីកិច្ចការហិរញ្ញវត្ថុ និងសមាសភាពគណៈកម្មាធិការផ្សេងៗគឺត្រូវធ្វើដោយសម្ងាត់ និងលាយលក្ខ័អក្សរការកត់ត្រាអំពីសមាសភាពអ្នកបោះឆ្នោត គឺជាការចាំបាច់។

៤.៨.៥. ចំពោះការបោះឆ្នោតលើករណីផ្សេងទៀត គឺត្រូវធ្វើដោយលើកដៃលើកលែងតែមានការបោះឆ្នោតសំរេចឱ្យធ្វើតាមទម្រង់ផ្សេងទៀត។

៤.៨.៦. ប្រធានអង្គប្រជុំ ទទួលខុសត្រូវពិភាក្សា និងកំណត់ទម្រង់បោះឆ្នោតយោងតាមបែបបទចែងក្នុងលក្ខន្តិកៈ និងគោលការណ៍ការងាររបស់ **គ.ស.ក.** ឬ **C.C.C.**។ សមាជិកទាំងឡាយបោះឆ្នោតស្នើប្រើទម្រង់ផ្សេងៗក្នុងការបោះឆ្នោត។

៤.៨.៧. រាល់បញ្ហាគោលការណ៍ដែលឆ្លងកាត់ការបោះឆ្នោត ត្រូវផ្សព្វផ្សាយជាលាយលក្ខ័អក្សរយ៉ាងហោចណាស់ ១០ថ្ងៃ មុនថ្ងៃកំណត់បោះឆ្នោត។ ប៉ុន្តែសមាជិកអាចលើកបញ្ហាលើការបោះឆ្នោតសំរេចនៅពេលអង្គប្រជុំ ហើយធ្វើការបោះឆ្នោតតែម្តងក្នុងពេលប្រជុំនោះ។

៤.៨.៨. សម្លេងឆ្នោតដែលអាចចាត់ទុកថាការអនុម័ត ÷

៤.៨.៨.១. ដើម្បីបញ្ចូលជាសមាជិក **គ.ស.ក.** ឬ **C.C.C.** ដើម្បីដល់សមាជិកភាព **គ.ស.ក.** ឬ **C.C.C.** ឬដើម្បីអនុម័ត គម្រោងថវិកាទាមទារសម្លេងឆ្នោតភាគច្រើន (៥០%+១) នៃសមាជិកភាពទាំងមូល។

៤.៨.៨.២. ដើម្បីកែប្រែលក្ខន្តិកៈកែប្រែគោលការណ៍ការងារនិងដើម្បីជ្រើសរើស/ដកចេញសមាជិក គណៈកម្មាធិការប្រតិបត្តិ គឺទាមទារសម្លេងពីរភាគបី នៃអង្គការសមាជិកទាំងអស់។

៤.៨.៨.៣.ចំពោះការបោះឆ្នោតរើសសមាសភាពគណៈកម្មាធិការនានាក្រៅពីគណៈកម្មាធិការប្រតិបត្តិ បេក្ខជនដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ គឺចាត់ទុកថាឈ្នះក្នុងអង្គប្រជុំដែលមាន Quorum សមស្រប ។

៤.៨.៨.៤. ចំពោះករណីផ្សេងៗទៀត ដែលត្រូវឆ្លងកាត់ការបោះឆ្នោត គឺទាមទារសម្លេង ៥០%+១ នៃចំនួនសមាជិកដែលមានវត្តមានដោយរាប់បញ្ចូលទាំងសម្លេងផ្ទេរសិទ្ធិផងដែរ ។

៤.៨.៩. ក្នុងករណីដែលចាំបាច់ហើយជាបន្ទាន់ដែល **គ.ស.ក.** ឬ **C.C.C.** ត្រូវការសេចក្តីសំរេចក៏ប៉ុន្តែពុំមាន Quorum ក្នុងអង្គប្រជុំការបោះឆ្នោតអាចប្រព្រឹត្តទៅបានក្នុងចំណោមសមាជិកដែលមានវត្តមានហើយលទ្ធផលជាស្ថាពរ គឺអាចទទួលបានតាមរយៈការស្នើឱ្យបោះឆ្នោតតាមប្រៃសណីយ៍ចំពោះសមាជិកដែលពុំមានវត្តមានមករួចប្រជុំ ។

៤.៨.១០. រាល់សេចក្តីសំរេចតាមសន្លឹកឆ្នោតដោយ **គ.ស.ក.** ឬ **C.C.C.** គឺពុំមានអានុភាពលើអង្គការសមាជិកទេ ក៏ប៉ុន្តែគណៈកម្មាធិការប្រតិបត្តិ និងបុគ្គលិក **គ.ស.ក.** ឬ **C.C.C.** គឺចាំបាច់ត្រូវអនុលោមតាមអ្វីដែលបានសំរេច ។

# ប្រការ ៥: គណៈកម្មាធិការប្រតិបត្តិ

## ៥.១. តួនាទីរបស់គណៈកម្មាធិការប្រតិបត្តិ

គណៈកម្មាធិការប្រតិបត្តិ ដើរតួនាទីជាក្រុមប្រឹក្សានាយកនៃអង្គការ **គ.ស.ក.** ឬ **C.C.C.** គណៈកម្មាធិការមានកិច្ចការចំបងដើម្បីណែនាំ និងផ្តល់យោបល់ដល់នាយកប្រតិបត្តិទៅលើការអភិវឌ្ឍគោលការណ៍ដែលសមាជិកអង្គការ **គ.ស.ក.** ឬ **C.C.C.** ចង់បាន ។ គណៈកម្មាធិការប្រតិបត្តិ មានការទទួលខុសត្រូវចំពោះសមាជិកភាពអង្គការ **គ.ស.ក.** ឬ **C.C.C.** គ្រប់ពេលវេលា ។ គណៈកម្មាធិការ បង្កើតគំរោងទូលំទូលាយមួយសំរាប់គោលការណ៍នានារបស់អង្គការ **គ.ស.ក.** ឬ **C.C.C.** ដែលត្រូវទទួល ការយល់ស្របពីសមាជិកភាពនៃអង្គការ **គ.ស.ក.** ឬ **C.C.C.** ។ គណៈកម្មាធិការប្រតិបត្តិជួយដល់ នាយកប្រតិបត្តិក្នុងការបកស្រាយអាណត្តិរបស់ខ្លួន និងបញ្ជាក់ថារាល់សកម្មភាពទាំងអស់ដែលអនុវត្តក្នុងនាមសមាជិកអង្គការ **គ.ស.ក.** ឬ **C.C.C.** ដោយនាយកប្រតិបត្តិឬសមាជិកនៃគណៈកម្មាធិការ ប្រតិបត្តិ ឬក៏បុគ្គលិកនៃអង្គការ **គ.ស.ក.** ឬ **C.C.C.** ស្ថិតនៅក្នុងអាណត្តិផ្តល់អោយដោយអង្គការជាសមាជិកព្រមទាំងប្រព្រឹត្តតាមការណ៍ដែលបានឯកភាពទូទៅ ។

## ៥.២. ភារៈកិច្ចនានានៃគណៈកម្មាធិការប្រតិបត្តិ

៥.២.១. គណៈកម្មាធិការប្រតិបត្តិនឹងធានានូវការគ្រប់គ្រងទូទៅអោយមានប្រសិទ្ធិភាព និងការទទួលខុសត្រូវរបស់អង្គការ **គ.ស.ក.** ឬ **C.C.C.** ចំពោះសមាជិកភាពនិងដៃគូរបស់ខ្លួនក្នុងវង្វង់ច្បាប់នៃប្រទេសកម្ពុជា ។

៥.២.២. គណៈកម្មាធិការប្រតិបត្តិនឹងរៀបចំគោលការណ៍ដោយមានការយល់ព្រមពីសមាជិកភាព និងជ្រើសយកសកម្មភាពដើម្បីឆ្លើយតបទៅនឹងរឿងហេតុផ្សេងៗ ដែលលើកឡើងដោយសមាជិកភាព ។

៥.២.៣. គណៈកម្មាធិការប្រតិបត្តិនឹងជ្រើសរើសយក និងអនុវត្តកិច្ចព្រមព្រៀងជាមួយនឹងនាយកប្រតិបត្តិ ។ គណៈកម្មាធិការនិងត្រួតពិនិត្យរាល់កិច្ចការទាំងអស់ដែលបានរៀបចំជាពិសេសសំរាប់នាយកប្រតិបត្តិ ហើយជាកិច្ចការដែលនាយកប្រតិបត្តិនឹងធានាខុសត្រូវជាដំបូង ។

៥.២.៤. គណៈកម្មាធិការប្រតិបត្តិ នឹងពិគ្រោះ ពិនិត្យ និងយល់ព្រមមុន និងបញ្ជូនចែក ឬប្រកាសជាផ្លូវការនូវឯកសារទាំងអស់ដែលបានព្រាងដោយនាយកប្រតិបត្តិ ដូចបានរាយនាមក្នុងបញ្ជីនៃប្រការ៧ នៃលក្ខន្តិកៈនេះ ។

៥.២.៥. សំណូមពរអោយមានការសំរេចនៃអង្គការ **គ.ស.ក.** ឬ **C.C.C.** ដោយសមាជិកនានាឬនាយកប្រតិបត្តិហួសពី ការប្រតិបត្តិធម្មតារបស់ការិយាល័យ **គ.ស.ក.** ឬ **C.C.C.** នឹងត្រូវបានរៀបចំតាមអាទិភាពដោយគណៈកម្មាធិការប្រតិបត្តិ ។

៥.២.៦. គ្មានសមាជិកណាមួយនៃគណៈកម្មាការប្រតិបត្តិ បុគ្គលិក ឬសមាជិកភាពនៃអង្គការ **គ.ស.ក.** ឬ **C.C.C.** អាចបង្ហាញខ្លួនទោះជាក្នុងការសរសេរ ឬក៏បញ្ចេញមុខជាអ្នកនាំពាក្យជាផ្លូវការនៃអង្គការ **គ.ស.ក.** ឬ **C.C.C.** ដោយពុំមានការតែងតាំងពីនាយកប្រតិបត្តិប្រធាននៃគណៈកម្មាធិការប្រតិបត្តិឬ ក៏សមាជិកភាពនៃអង្គការ **គ.ស.ក.** ឬ **C.C.C.** ដើម្បីទៅបកស្រាយក្នុងនាមអង្គការ **គ.ស.ក.** ឬ **C.C.C.** អំពីបញ្ហាអ្វីមួយ ។ អាជ្ញាធរដែលផ្តល់នូវការទទួលខុសត្រូវនេះត្រូវតែអនុវត្តតាមគោលការណ៍សំរាប់ការ ទំនាក់ទំនងពតិមានជាផ្លូវការដូចមានចែងក្នុងប្រការ៧នៃលក្ខន្តិកៈ ។

៥.២.៧. គណៈកម្មាធិការប្រតិបត្តិ នឹងធានានូវការរៀបចំអង្គប្រជុំសាមញ្ញប្រចាំឆ្នាំដែលក្នុងពេលនោះរបាយការណ៍ប្រចាំឆ្នាំ និងការត្រួតពិនិត្យហិរញ្ញកិច្ចប្រចាំឆ្នាំ និងត្រូវយកមកបកស្រាយ ។

៥.២.៨. គណៈកម្មាធិការប្រតិបត្តិ និងបង្កើត និងរំសាយគណៈកម្មការនានា តាមសេចក្តីត្រូវការដើម្បីបំពេញនូវគោលដៅទាំងឡាយរបស់អង្គការ **គ.ស.ក.** ឬ **C.C.C.** ដូចបានចែងក្នុងប្រការ៥ ។

៥.២.៩. គណៈកម្មាធិការប្រតិបត្តិនិងរៀបចំកម្មវិធីប្រជុំមួយ និងជួបប្រជុំគ្នាយ៉ាងតិច ៤ដងក្នុង១ឆ្នាំ ។

គណៈកម្មាធិការប្រតិបត្តិនឹងអាចធ្វើការប្រជុំពិសេស១ទៅតាមកាលៈទេសៈដែលត្រូវការចាំបាច់។

៥.២.១០. គណៈកម្មាធិការប្រតិបត្តិការនិងតាមដានពិនិត្យកិច្ចការហិរញ្ញវត្ថុនៃអង្គការ **គ.ស.ក.** ឬ **C.C.C.** ដែលបានអនុវត្តដោយបុគ្គលិក និងទទួលខុសត្រូវក្នុងការចុះហត្ថលេខានៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងឡាយក្រោយពីការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិ។

៥.២.១១. គណៈកម្មាធិការប្រតិបត្តិនិងទទួលធានាខុសត្រូវនូវកិច្ចការសំរេចបាន និងធានារ៉ាប់រងផ្នែកហិរញ្ញវត្ថុរបស់អង្គការ **គ.ស.ក.** ឬ **C.C.C.** ហើយគណៈកម្មាធិការប្រតិបត្តិនិងអាចមានសិទ្ធិចុះហត្ថលេខាទៅលើកិច្ចការហិរញ្ញវត្ថុផ្សេង១ ក្នុងរង្វង់កំណត់អនុញ្ញាតិដោយគណៈកម្មាធិការប្រតិបត្តិរៀងរាល់ឆ្នាំក្នុងការប្រជុំលើកដំបូងនៃគណៈកម្មាធិការប្រតិបត្តិបន្ទាប់ពីអង្គប្រជុំវិសាមញ្ញប្រចាំឆ្នាំចប់ភ្លាម។

## ៥.៣. ភារកិច្ចរបស់សមាជិកនៃគណៈកម្មាធិការប្រតិបត្តិ

៥.៣.១. ប្រធាន ឬក៏អនុប្រធានក្នុងការអវត្តមានរបស់ប្រធាន និងធ្វើជាប្រធានអង្គប្រជុំផ្សេង១ទៀតរបស់អង្គការ **គ.ស.ក.** ឬ **C.C.C.** ឬក៏អង្គប្រជុំផ្សេង១នៃគណៈកម្មាធិការប្រតិបត្តិ ។

៥.៣.២. ប្រធាននឹងទទួលខុសត្រូវរ៉ាប់រងក្នុងការអនុញ្ញាតបញ្ចេញនូវកំណត់ហេតុរបាយការណ៍ និងរាល់ឯកសារទាំងអស់ដែលជាកម្មសិទ្ធិរបស់អង្គការ **គ.ស.ក.** ឬ **C.C.C.** តាមការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិ។

៥.៣.៣. អនុប្រធាន និងសមាជិកសង្កេតការណ៍នៃគណៈកម្មាធិការប្រតិបត្តិ និងផ្តល់ជាជំនួយការដល់សមាជិកពេញសិទ្ធិដទៃទៀតនៃគណៈកម្មាធិការប្រតិបត្តិតាមសំណូមពររបស់ប្រធាន និងអាចទទួលការបែងចែកទទួលខុសត្រូវផ្សេង១យោងទៅលើកិច្ចការងារសំខាន់១ដូចតទៅ ÷

១. ហិរញ្ញវត្ថុ និងការស្វែងរកមូលនិធិ

២. សមាជិកភាព

៣. គ្រប់គ្រងបុគ្គលិក និងរកបុគ្គលិកមកកាន់ការ ហើយនិង

៤. កិច្ចការផ្សេង១ទៀត ដែលអាចត្រូវប្រគល់អោយម្តងម្កាល។

## ៥.៤. នីតិវិធីនៃការបោះឆ្នោតសំរាប់គណៈកម្មាធិការប្រតិបត្តិ

៥.៤.១. សមាជិកជាបុគ្គលិកនៃអង្គការជាសមាជិកអាចជ្រើសរើសអោយឈរឈ្មោះនូវបុគ្គលដែលមានលទ្ធភាព ដើម្បីមកបំរើការងារក្នុងគណៈកម្មាធិការប្រតិបត្តិ។

៥.៤.២. លិខិតបំពេញសំរាប់ឈរឈ្មោះនឹងត្រូវផ្តល់អោយហើយត្រូវតែបំពេញដើម្បីអោយការឈរឈ្មោះមានប្រសិទ្ធភាពដោយមានការឯកភាពពីបុគ្គលដែលត្រូវគេជ្រើសរើសអោយឈរឈ្មោះនោះរួមបញ្ចូលផង។

៥.៤.៣. ការឈរឈ្មោះទាំងនេះ នឹងត្រូវទទួលយកក្នុងកំឡុងពេលយ៉ាងតិចបំផុត ៤ សប្តាហ៍ មុនការបោះឆ្នោត ហើយឈ្មោះនៃបុគ្គលឈរឈ្មោះទាំងឡាយនឹងត្រូវបិទប្រកាសនៅឯការិយាល័យក្នុងខណៈពេលដែលបានទទួល ។

៥.៤.៤. កាលបរិច្ឆេទបញ្ចប់នៃការជ្រើសរើសអោយឈរឈ្មោះ និងត្រូវកំណត់ពេល ២ សប្តាហ៍មុនការបោះឆ្នោត ។

៥.៤.៥. បញ្ជីនៃអ្នកឈរឈ្មោះទាំងអស់នឹងត្រូវបញ្ជូនចែកទៅអោយសមាជិកពេញសិទ្ធិទាំងឡាយ ក្នុងរយៈពេល ១០ថ្ងៃ មុនការបោះឆ្នោត ។

៥.៤.៦. ការបោះឆ្នោតរើសសមាជិកគណៈកម្មាធិការប្រតិបត្តិនឹងត្រូវរៀបចំធ្វើឡើង១ដងជាប្រចាំឆ្នាំ។ រយៈពេលកាន់តំណែងគឺសំរាប់២ឆ្នាំ។ សមាជិកនិមួយៗនៃគណៈកម្មាធិការប្រតិបត្តិនិងត្រូវបំរើការងាររយៈពេល២ឆ្នាំ ប៉ុន្តែគ្មានសមាជិកណាមួយនឹងអាចបំរើការងារលើសពី ២ដងនៃរយៈពេលកាន់តំណែងនោះទេ។

## ៥.៥. បែបបទការងារ:

៥.៥.១. នៅពេលប្រជុំលើកដំបូង បន្ទាប់ពីអង្គប្រជុំវិសាមញ្ញប្រចាំឆ្នាំគណៈកម្មាធិការប្រតិបត្តិ និងឯកភាពទៅលើទំរង់ការប្រតិបត្តិសំរាប់ការប្រជុំផ្សេងៗរបស់ខ្លួនដែលសមស្របទៅតាមធម្មនុញ្ញ និងលក្ខន្តិកៈនៃអង្គការ **គ.ស.ក.** ឬ **C.C.C.** ។

៥.៥.២. កាលវិភាគសំរាប់អង្គប្រជុំទាំងអស់នៃគណៈកម្មាធិការប្រតិបត្តិ នឹងត្រូវបិទប្រកាសនៅអង្គការ **គ.ស.ក.** ឬ **C.C.C.** ។

៥.៥.៣. អង្គការជាសមាជិកអាចធ្វើសំណូមពរគ្រប់ពេលវេលាជួបជាមួយគណៈកម្មាធិការប្រតិបត្តិដើម្បីពិគ្រោះអំពីកិច្ចការសំខាន់ៗ។

៥.៥.៤. ដើម្បីឱ្យមានការសំរេចចិត្តណាមួយដោយគណៈកម្មាការប្រតិបត្តិ សមាជិកពេញសិទ្ធិភាគច្រើននៃគណៈកម្មាធិការត្រូវមានវត្តមាន ហើយយ៉ាងតិចណាស់ក៏ចំនួនភាគច្រើននៃអ្នកដែលមានវត្តមានត្រូវមានការឯកភាពនឹងគ្នា។

៥.៥.៥. ការសំរេចចិត្តជាសាមញ្ញផ្សេងៗ និងត្រូវធ្វើឡើងដោយគណៈកម្មាធិការក្នុងពេលប្រជុំមិនមែនតាមរយៈការពិគ្រោះដោយខ្លួនទេធ្វើដូច្នេះ គឺដើម្បីជំរុញអោយមានការពិភាក្សាគ្នាការដឹងឮនូវទស្សនៈផ្សេងៗពីគ្នាការអនុវត្តប្រកបដោយជំនាញខ្ពស់នូវកិច្ចធុរៈរបស់អង្គការ **គ.ស.ក.** ឬ **C.C.C.** និងការទទួលខុសត្រូវនៃសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការក្នុងការចូលរួមអង្គប្រជុំនានា ។

៥.៥.៦. ចំពោះកិច្ចការផ្សេងៗទាក់ទងនឹងបុគ្គលិក ឬការពាក់ព័ន្ធដទៃទៀត ដែលពិបាកដោះស្រាយ

គណៈកម្មាធិការប្រតិបត្តិអាចជ្រើសយកការប្រជុំមិនចំហរមួយ។

## ៥.៦. កំណត់ហេតុនៃអង្គប្រជុំ និងវត្តមាន

៥.៦.១. កំណត់ហេតុផ្សេងៗ រួមទាំងការចូលរួមនៃអង្គប្រជុំទាំងអស់នៃគណៈកម្មាធិការប្រតិបត្តិ និងត្រូវរក្សាទុកដោយនាយកប្រតិបត្តិ ឬសមាជិកចាត់តាំងម្នាក់នៃគណៈកម្មាធិការប្រតិបត្តិក្នុងករណីដែលមានសម័យប្រជុំដោយមិនចំហរមួយ នៅពេលដែលនាយកប្រតិបត្តិមានការអវត្តមាន។

៥.៦.២. កំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិទាំងឡាយត្រូវមានជាប្រចាំ ដើម្បីឱ្យសមាជិកភាពធ្វើការត្រួតពិនិត្យប៉ុន្តែកំណត់ហេតុនៃសម័យប្រជុំដោយមិនចំហរមិនអាចផ្តល់សមាជិកភាពបានទេ បើសិនជាគ្មានការអនុញ្ញាតិច្បាស់លាស់តាមរយៈពេលការបោះឆ្នោតមួយជាឯកច្ឆ័ននៃគណៈកម្មាធិការប្រតិបត្តិ។

៥.៦.៣. ក្នុងភារកិច្ចអនុវត្តការមិនលាក់បាំង និងភាពជាចំហរសមាជិកពេញសិទ្ធិទាំងឡាយនៃគណៈកម្មាធិការប្រតិបត្តិ និងគោរពនូវអ្វីដែលចាត់ទុកថាមិនអាចផ្សព្វផ្សាយបានជាចាំបាច់ដើម្បីរក្សានូវភាពសុចរិតនៃអង្គការ **គ.ស.ក.** ឬ **C.C.C.** សន្តិសុខនៃបុគ្គលម្នាក់ៗ និងផលប្រយោជន៍ផ្សេងៗនៃអង្គការជាសមាជិករបស់ **គ.ស.ក.** ឬ **C.C.C.**។

## ៥.៧. ការរំលាយគណៈកម្មាធិការប្រតិបត្តិ

៥.៧.១. គណៈកម្មាធិការប្រតិបត្តិទាំងមូលអាចតែងតាំង ឬរំលាយដោយយោងតាមលក្ខណៈដូចខាងក្រោមនេះ ÷

៥.៧.១.១. ការសំរេចចិត្តមួយធ្វើឡើងដោយចំនួន ៥០% + ១ នៃសមាជិកទាំងអស់អាចរំលាយគណៈកម្មាធិការប្រតិបត្តិ និងរៀបចំការបោះឆ្នោតជាថ្មី។

៥.៧.២. សមាជិកនិមួយៗនៃគណៈកម្មាធិការប្រតិបត្តិអាចរំលាយដោយយោងតាមលក្ខណៈខាងក្រោម:

៥.៧.២.១. ការចប់អាណត្តិនៃរយៈពេលកាន់តំណែងការងារ។

៥.៧.២.២. ការសំរេចចិត្តមួយធ្វើឡើងដោយចំនួន ៥០% + ១ នៃសមាជិកទាំងអស់ដើម្បីរំលាយសមាជិកណាម្នាក់។

៥.៧.២.៣.សមាជិកនៃគណៈកម្មាធិការប្រតិបត្តិដែលត្រូវបញ្ឈប់ជាបុគ្គលិកសមាជិកនៃអង្គការសមាជិកណាមួយរបស់ **គ.ស.ក.** ឬ **C.C.C.** ដោយសារអង្គការនោះបញ្ឈប់ជាសមាជិកភាពក្នុងអង្គការ **គ.ស.ក.** ឬ **C.C.C.** ឬក៏សមាជិកបុគ្គលិកនោះចាកចេញពីការងារនៃអង្គការជាសមាជិក។ សមាជិកបុគ្គលិកនោះអាចមានសិទ្ធិឈរឈ្មោះបោះឆ្នោតម្តងទៀត និងបំរើ

ការងារក្នុងគណៈកម្មាធិការប្រតិបត្តិបើសិនជាមានការងារធ្វើនៅអង្គការជាសមាជិកមួយទៀត ។

៥.៧.២.៤. ក្នុងករណីសមាជិកគណៈកម្មាធិការប្រតិបត្តិណាម្នាក់មានការអវត្តមាន ឬមិនបានចូលរួមការប្រជុំគណៈកម្មាធិការ០៣ ( បី ) ដងជាប់ៗគ្នាអាចនឹងមានសំណើរឱ្យលាលែងពីសមាជិកគណៈកម្មាធិការ ។

## ប្រការ ៦: គណៈកម្មាធិការនានា

### ៦.១. ការតែងតាំងគណៈកម្មាធិការនានា ( ក្រៅពីគណៈកម្មាធិការប្រតិបត្តិ)

៦.១.១. គណៈកម្មាធិការប្រតិបត្តិអាចបង្កើតនូវអនុគណៈកម្មការ និងគណៈកម្មការពិសេសបើសិនជាបានយល់ឃើញថាជាការត្រឹមត្រូវ ឬក៏បានទទួលសំណូមពរពីសមាជិកពេញសិទ្ធិទាំងឡាយ ។

៦.១.១.១.គោលបំណងនៃអនុគណៈកម្មការគឺផ្តល់ជាជំនួយដល់គណៈកម្មាធិការប្រតិបត្តិក្នុងកិច្ចការផ្សេងៗដូចជាស្ថានភាពហិរញ្ញវត្ថុ និងសមាជិកភាព ។ គណៈកម្មការពិសេស និងត្រូវបង្កើតឡើងដើម្បីអនុវត្តកិច្ចការចាំបាច់ផ្សេងៗ ។

៦.១.១.២. រយៈពេលបំរើការងារនៃគណៈកម្មការទាំងនេះនិងអាស្រ័យទៅលើប្រភេទនៃកិច្ចការរបស់ គណៈកម្មការ ហើយដែលនឹងត្រូវកំណត់នៅពេលដែលបានជ្រើសតាំង ។

៦.១.២. សមាជិកនៃគណៈកម្មការបែបនេះ នឹងត្រូវទទួលតំណែងផ្តល់ឱ្យដោយគណៈកម្មាធិការប្រតិបត្តិក្រោយពីសមាជិកទាំងនោះបានទទួលយល់ព្រមពីសមាជិកពេញសិទ្ធិទាំងឡាយក្នុងសម័យប្រជុំទៀងទាត់មួយ ដោយការលើកដៃដែលមានចំនួនត្រូវការចាំបាច់ ។

៦.១.៣. លក្ខណៈអនុវត្តការងារសំរាប់គណៈកម្មការទាំងអស់នឹងត្រូវបង្កើតឡើងដោយគណៈកម្មាធិការប្រតិបត្តិ ។

### ៦.២. សិទ្ធិចូលរួមនៅក្នុងគណៈកម្មាធិការនានា

៦.២.១. សមាជិកពេញសិទ្ធិ នៃគណៈកម្មការដែលត្រូវអាចជ្រើសយកបាន គឺក្នុងចំណោមបុគ្គលិកនៃអង្គការជាសមាជិកពេញសិទ្ធិ ឬក៏អង្គការជាសមាជិកចូលរួម ។

៦.២.២. គ្រប់អង្គការជាសមាជិកអាចជ្រើសរើសបុគ្គលដែលមានសិទ្ធិអោយឈរឈ្មោះដើម្បីបំរើការងារក្នុងគណៈកម្មការផ្សេងៗរបស់អង្គការ **គ.ស.ក.** ឬ **C.C.C.** ។

៦.២.៣. អ្នកតំណាងនៃអង្គការនានាដែលមិនមែនជាសមាជិកភាពនៃ **គ.ស.ក.** ឬ **C.C.C.** អាចត្រូវបានអញ្ជើញចូល រួមពីគណៈកម្មាធិការប្រតិបត្តិបើសិនការអញ្ជើញនេះមានភាពត្រឹមត្រូវតាមលក្ខណៈ ។

៦.២.៤. អនុគណៈកម្មការនិមួយៗត្រូវមានសមាជិកចាត់តាំងម្នាក់ក្នុងគណៈកម្មាធិការប្រតិបត្តិ។

៦.២.៤.១.បើសិនជាសមាជិកចាត់តាំងដោយគ្មានសំលេងឆ្នោតក្នុងអនុគណៈកម្មការមានការអវត្តមានក្នុងសម័យប្រជុំមួយ គណៈកម្មាធិការប្រតិបត្តិនឹងខិតខំគ្រប់លទ្ធភាពដើម្បីរកសមាជិកពេញសិទ្ធិរបស់ខ្លួនម្នាក់ទៀតអោយមកបំរើកិច្ចការតាមរយៈការផ្ទេរសិទ្ធិរបស់បុគ្គលដែលអវត្តមាន។

៦.២.៤.២. បើសិនជាអនុគណៈកម្មការមួយនៅសេសសល់សមាជិកពេញសិទ្ធិតិចជាង ៣រូប ហើយនៅសេសសល់ជាង ២ខែទៀតនៃរយៈពេលកាន់តំណែងរបស់ពួកគេគណៈកម្មការប្រតិបត្តិនិងចាត់តាំង សមាជិកថ្មីអោយមកបំពេញកន្លែងដែលបាត់បង់សមាជិក។

## ៦.៣. បែបបទអនុវត្តការងាររបស់គណៈកម្មាធិការ

៦.៣.១. ប្រធាននៃគណៈកម្មាធិការនិមួយៗ នឹងត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកពេញសិទ្ធិនៃគណៈកម្មការហើយសមាជិកពេញសិទ្ធិនៃគណៈកម្មការអាចត្រូវបានចាត់តាំងអោយឈរឈ្មោះកាន់តំណែងជាប្រធាន។

# ប្រការ ៧: នាយកប្រតិបត្តិនៃ គ.ស.ក. ឬ C.C.C.

## ៧.១. អាណត្តិ តួនាទី និងភារកិច្ចនៃនាយកប្រតិបត្តិ

៧.១.១.នាយកប្រតិបត្តិនឹងត្រូវបានជ្រើសរើសមនុស្សដែលមានសមត្ថភាពសមរម្យសំរាប់បំពេញការងារមួយអាណត្តិដំបូងដែលមានរយៈពេល២ឆ្នាំ។ នាយកប្រតិបត្តិអាចបន្តអាណត្តិរបស់ខ្លួនបានចំនួន ៥ ឆ្នាំ ប្រសិនបើការបំពេញការងារប្រដោយការពេញចិត្ត។

៧.១.១.១. នាយកប្រតិបត្តិ គឺគ្មានសិទ្ធិបោះឆ្នោត (Ex officio) ហើយជាសមាជិកក្រៅផ្លូវការនៃគណៈកម្មាធិការប្រតិបត្តិ។

៧.១.១.២. នាយកប្រតិបត្តិ គឺបំរើគណៈកម្មាធិការប្រតិបត្តិជាលេខាធិការ បុគ្គលនេះមានតួនាទីរៀបចំអង្គប្រជុំនៃគណៈកម្មាធិការប្រតិបត្តិដោយរាប់ទាំងការរៀបចំរបៀបវារៈ។ នាយកប្រតិបត្តិ នឹងស្នើរយោបល់គណៈកម្មាធិការប្រតិបត្តិ ចំពោះរាល់បណ្តាគោលការណ៍ដែលពាក់ព័ន្ធនឹងទំនាក់ទំនងរវាង **គ.ស.ក.** ឬ C.C.C. និងសមាជិកទាំងអស់។ បុគ្គលរូបនេះគឺត្រូវព្យាយាមធ្វើយ៉ាងណាឱ្យការិយាល័យ **គ.ស.ក.** ឬ C.C.C. អនុវត្តយ៉ាងសមស្របនូវរាល់ការសំរេច និងគំរោងផែនការដែលអនុម័តដោយគណៈកម្មាធិការប្រតិបត្តិ។ បុគ្គលរូបនេះគឺត្រូវសហការហើយប្រឹក្សាយ៉ាងជិតស្និទ្ធជាមួយអនុប្រធាន **គ.ស.ក.** ឬ C.C.C.។

៧.២.១. ភារកិច្ចដទៃទៀត នៃនាយកប្រតិបត្តិនិងការទទួលខុសត្រូវគឺចែងដូចខាងក្រោមនេះ ÷

១). រៀបចំសំណើរៃអង្គាសថវិកានានា ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិដើម្បីឆ្លងការឯកភាពអំពីសំណើទាំងនោះ ។

២). បង្កលក្ខណៈឱ្យមានការចុះត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុប្រចាំឆ្នាំនៅ **គ.ស.ក.** ឬ **C.C.C.** ។

៣). រៀបចំកាលវិភាគនៃពិធីនានា និងផែនការការងារប្រចាំឆ្នាំសំរាប់ **គ.ស.ក.** ឬ **C.C.C.** ។

៤). លើករបៀបវារៈនៃរាល់អង្គប្រជុំនៃ **គ.ស.ក.** ឬ **C.C.C.** ដើម្បីឆ្លងការឯកភាពពីគណៈកម្មាធិការប្រតិបត្តិ ។

៥). បើសិនជាមានការឯកភាពពីគណៈកម្មាធិការប្រតិបត្តិ នាយកប្រតិបត្តិអាចបំពេញតួនាទីជាតំណាង **គ.ស.ក.** ឬ **C.C.C.** ដើម្បីជួប ឬទាក់ទងនឹងអង្គការសមាជិក ស្ថាប័នជាតិឬអង្គការនានា។ បុគ្គលរូបនេះ ត្រូវធ្វើយ៉ាងឱ្យមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរាល់ស្ថាប័នរដ្ឋបាលសមស្របទាំងក្នុង និងក្រៅរដ្ឋាភិបាលធ្វើជាខ្សែរយៈជាមួយទីភ្នាក់ងារទ្វេភាគី និងចតុភាគីដែលមានវត្តមាននៅកម្ពុជា ហើយវិភាគរករាល់លក្ខណៈដែលអាចផ្តល់ការជួយគ្នាទៅវិញទៅមក និងសហប្រតិបត្តិការរវាងគ្នានិងគ្នា។ រាល់ការទំនាក់ទំនងជាមួយភាគីខាងក្រៅ **គ.ស.ក.** ឬ **C.C.C.** នេះគឺត្រូវអនុវត្តតាមគោល ការណ៍កំណត់ដោយគណៈកម្មាធិការប្រតិបត្តិ ។

៦). ភារកិច្ចចំបងនៃនាយកប្រតិបត្តិ គឺព្យាយាមធ្វើយ៉ាងណាឱ្យបុគ្គលិក **គ.ស.ក.** ឬ **C.C.C.** ទាំងអស់មានកិច្ចសន្យាប្រកបការងារ ដែលក្នុងនេះមានចែងយ៉ាងច្បាស់លាស់អំពីភារកិច្ចនានាព្រមជាមួយលក្ខខណ្ឌនៃការប្រកបអាជីព។ យ៉ាងហោចណាស់មួយដង រៀងរាល់ឆ្នាំនាយកប្រតិបត្តិត្រូវធ្វើរបាយការណ៍អំពីភារកិច្ច ការប្រគល់សិទ្ធិបន្តដើម្បីធ្វើការងារ (delegation of authorities) និងលក្ខខណ្ឌនៃការប្រកបអាជីពនៃបុគ្គលិក **គ.ស.ក.** ឬ **C.C.C.** ដាក់ជូនគណៈកម្មាធិការប្រតិបត្តិដើម្បីស្នើការឯកភាព ។

៧). ភារកិច្ចចំបងនៃនាយកប្រតិបត្តិ គឺគ្រប់គ្រងកិច្ចការប្រចាំថ្ងៃ និងលក្ខណៈរួមនៃការប្រកបការងារនៃបុគ្គលិកទាំងអស់នៃ **គ.ស.ក.** ឬ **C.C.C.** ។ នាយកប្រតិបត្តិត្រូវព្យាយាមធ្វើយ៉ាងណាឱ្យបុគ្គលិក **គ.ស.ក.** ឬ **C.C.C.** ទាំងអស់ទទួលការវាយតំលៃអំពីការងាររបស់ខ្លួនយ៉ាងសមស្របនិងយ៉ាងទៀងទាត់ដោយផ្អែកលើគោលការណ៍ និងបទបញ្ញត្តិដែលមានកំណត់។ ទោះបីជានាយកប្រតិបត្តិ ទទួលខុសត្រូវលើការជ្រើសរើស និងបញ្ឈប់បុគ្គលិកធ្វើការនៅ **គ.ស.ក.** ឬ **C.C.C.** ទាំងអស់ នាយកប្រតិបត្តិត្រូវព្យាយាមចាត់តាំងឱ្យមានបែបបទសមស្របសំរាប់គ្រប់គ្រងបុគ្គលិក ហើយធ្វើយ៉ាងណាឱ្យទំរង់បែបបទនេះដំណើរការតាមការកំណត់ ។

៨). នាយកប្រតិបត្តិ គឺទទួលខុសត្រូវលើសុខុមាលភាព និងសុវត្ថិភាពនៃបុគ្គលិកទាំងអស់នៃ

**គ.ស.ក.** ឬ **C.C.C**. ហើយត្រូវពិគ្រោះជាមួយគណៈកម្មាធិការប្រតិបត្តិ (បើសិនជាសមស្រប) អំពីបញ្ហាផ្សេងៗពាក់ពន្ធ័នឹងបុគ្គលិក។

៩). តាមរយៈគណៈកម្មាធិការប្រតិបត្តិ នាយកប្រតិបត្តិ ផ្តួចផ្តើមហើយបង្កលក្ខណៈឱ្យមានគោលការណ៍រដ្ឋបាលនានា ដែលតែងតាំងដោយគណៈកម្មាធិារប្រតិបត្តិ ឬអង្គការសមាជិក។ នាយកប្រតិបត្តិ ត្រូវស្នើការឯកភាពលើគោលការណ៍ទាំងនោះពីគណៈកម្មាធិការប្រតិបត្តិនៃសមាជិកភាព។

១០).ទោះបីជាគណៈកម្មាធិការប្រតិបត្តិទទួលខុសត្រូវលើរាល់ការសំរេចផ្នែកហិរញ្ញវត្ថុ និងចំណាយទាំងឡាយនៃ **គ.ស.ក.** ឬ **C.C.C.** នាយកប្រតិបត្តិមានភារកិច្ចពិនិត្យផ្ទាល់លើរាល់ទំរង់រដ្ឋបាល ប្រពន្ធ័ហិរញ្ញវត្ថុ (កាលណាចាំបាច់ និងសមស្រប) លើកិច្ចការរបស់គណនេយ្យករ (Accountant) នៃ **គ.ស.ក.** ឬ **C.C.C.**។

១១). រាល់លិខិតផ្លូវការផ្ញើជូនក្រសួងនានានៃរាជរដ្ឋាភិបាលកម្ពុជា ឬប្រមុខរដ្ឋទាមទារឱ្យមានហត្ថលេខានៃនាយកប្រតិបត្តិ និងប្រធានគណៈកម្មាធិការប្រតិបត្តិ ហើយត្រូវឆ្លងគណៈកម្មាធិការប្រតិបត្តិជាមុនសិន។

១២). គណៈកម្មាធិការប្រតិបត្តិនឹងផ្តល់សិទ្ធិពិសេសដើម្បីចុះហត្ថលេខាដល់នាយកប្រតិបត្តិ ដើម្បីកិច្ចការហិរញ្ញវត្ថុ នឹងលិខិតផ្សេងៗ។ ជាគោលការណ៍កិច្ចសន្យា (Contracts) នានា និងឯកសារដែលជាលក្ខណៈច្បាប់ចាត់ទុកជាផ្លូវការ គឺត្រូវចុះហត្ថលេខាដោយនាយកប្រតិបត្តិ។ គណៈកម្មាធិការប្រតិបត្តិអាច (តាមការវិភាគរបស់ខ្លួន) ស្នើឱ្យប្រធានគណៈកម្មាធិការប្រតិបត្តិចុះហត្ថលេខារួមជាមួយនាយកប្រតិបត្តិលើឯកសារនានា។

## ប្រការ ៨: ហិរញ្ញវត្ថុ

### ៨.១. គម្រោងថវិកា

គម្រោងថវិកាប្រចាំឆ្នាំ គឺត្រូវរៀបចំដោយនាយកប្រតិបត្តិដោយមានជំនួយការពីគណៈកម្មាធិការហិរញ្ញិកសំរាប់បង្ហាញជូន និងសុំការអនុមតិពីគណៈកម្មាធិការប្រតិបត្តិដោយសម្លេង ៥០%+១។

### ៨.២. ចំណាយក្រៅគម្រោងថវិកានានា

ក្នុងករណីដែលមានការចំណាយនានាដែលលើសពី USS 5,000 ហើយឥតមានគ្រោងទុកជាមុន ហើយដែលជាហេតុធ្វើឱ្យមានការប៉ះពាល់ដល់ការផ្តល់សេវាកម្មទាំងឡាយ ឬរាំងស្ទះអង្គប្រជុំនានាដែលបានកំណត់ជាមុនគណៈកម្មាធិការប្រតិបត្តិ ចាំបាច់ត្រូវជំរាបសមាជិកភាពឱ្យបានដឹង

ជាមុនអំពីមូលហេតុ និងទឹកប្រាក់នៃការចំណាយទាំងនោះ។ បើសិនជា ២០% នៃសមាជិកភាព ជូនដំណឹងមកគណៈកម្មាធិការប្រតិបត្តិថា ករណីនេះទាមទារឱ្យមានការបោះឆ្នោតអនុម័ត (ក្នុងរយៈពេល ១៥ថ្ងៃ) ដូច្នេះហើយចំណាយនេះពុំអាចធ្វើទៅបានទេ លុះត្រាតែមានការបោះឆ្នោតឯកភាពជាមុនសិន។

## ៤.៣. កម្រៃសមាជិកភាព

កម្រៃសមាជិកភាព គឺកំណត់ដោយយោងតាមការប៉ាន់ស្មានលើគំរោងថវិកាផ្នែករដ្ឋបាល និងផ្នែកកម្មវិធីនៃឆ្នាំបន្ទាប់ ( គំរោងថវិកាសំរាប់ក្នុងស្រុក )។ ជាធម្មតា គឺជាគំរោងថវិកាដែលត្រូវដាក់ជូនអ្នកជំនាញពិនិត្យ បិទបញ្ជីហិរញ្ញវត្ថុ (Auditors)។

៤.៣.១. កម្រៃសមាជិកភាព គឺត្រូវបង់ថ្ងៃទី ១ ខែ មករា រៀងរាល់ឆ្នាំ។

## ៤.៤. ការរៃអង្គាសថវិកា

រាល់ការរៃអង្គាសថវិកាសំរាប់មូលហេតុផ្សេងៗ គឺត្រូវផ្តួចផ្តើម និងមានការឯកភាពពីគណៈកម្មាធិការប្រតិបត្តិ។

## ៤.៥. អំណោយបានមកពីអង្គការដែលពុំមែនជាសមាជិក

រាល់ការទទួលអំណោយជាសាច់ប្រាក់ (Cash donations) ឬក៏ជាសំភារៈ (in kind donation) ពីប្រភពដែលពុំមែនជាអង្គការសមាជិក គឺចាំបាច់ត្រូវមានការឯកភាពពីគណៈកម្មាធិការប្រតិបត្តិ។

## ៤.៦. របាយការណ៍ហិរញ្ញវត្ថុនានា

របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសនានា គឺត្រូវផ្សព្វផ្សាយជូនដល់គ្រប់អង្គការសមាជិក។

## ៤.៧. ការចុះពិនិត្យបញ្ជីហិរញ្ញវត្ថុ

នាយកប្រតិបត្តិទទួលបន្ទុកបង្កលក្ខណៈឱ្យមានការចុះត្រួតពិនិត្យបិទបញ្ជីហិរញ្ញវត្ថុ (សវនកម្ម) ប្រចាំឆ្នាំ (yearly audit)។ អ្នកចុះត្រួតពិនិត្យ គឺឧទ្ទេសនាមដោយនាយកប្រតិបត្តិចំពោះមុខគណៈកម្មាធិការប្រតិបត្តិដើម្បីស្នើការឯកភាព។ របាយការណ៍នៃអ្នកត្រួតពិនិត្យបិទបញ្ជី និងឯកសារអំពីការគ្រប់គ្រងគឺត្រូវប្រគល់ជូនគណៈកម្មាធិការប្រតិបត្តិដើម្បីផ្ញើជូនសមាជិកអង្គការ។

បានតម្កល់ទុក លក្ខន្តិកៈ...[illegible]

នៅក្រសួងមហាផ្ទៃ តាមលិខិតលេខ..[illegible]

ចុះថ្ងៃទី..១៨....ខែ..តុលា.....ឆ្នាំ២០១១

ភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១

នាយកដ្ឋានកិច្ចការនយោបាយ

ប្រធាន

ឌី_សុភផាន

ធម្មនុញ្ញ និងលក្ខន្តិកៈនេះត្រូវបានពិនិត្យ និងអនុម័តដោយគណៈកម្មាធិការប្រតិបត្តិនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨

| ល.រ. | ឈ្មោះ តួនាទី និងឈ្មោះអង្គការ | ហត្ថលេខា |
|---|---|---|
| ១ | លោក ម៉ម សម្បត្តិ<br>នាយកប្រតិបត្តិ<br>អង្គការសកម្មភាពជាដៃគូ និង អភិវឌ្ឍន៍ (DPA) | |
| ២ | លោក ស្រី ហៃឌី អ៊ែ ដុព្យ<br>ប្រធានអង្គភាពទំនាក់ទំនង និង តស៊ូមតិ<br>អង្គការទស្សនៈពិភពលោក កម្ពុជា (WVC) | |
| ៣ | លោក ឈួន វឌ្ឍី<br>ប្រធានអង្គការធនធានមនុស្ស<br>អង្គការលូថេរ៉ែនបំរើពិភពលោក (LWF) | |
| ៤ | លោកស្រី ការូឡាញ កូស្លែន<br>អ្នកសម្របសម្រួលកម្មវិធី<br>អង្គការឃែរ (CARE) កម្ពុជា | |
| ៥ | លោក ប៉ែន សារ៉ាក់ ភាព<br>ប្រធានអង្គការធនធានមនុស្ស<br>អង្គការឃែរ (CARE) កម្ពុជា | |
| ៦ | លោក កូ ណារ៉ែន<br>ប្រធានអង្គភាពហិរញ្ញវត្ថុ និង រដ្ឋបាល<br>អង្គការ Forum Syd | |
| ៧ | លោកស្រី ម៉ារី ហ្លូត់<br>ប្រធានប្រចាំប្រទេស កម្ពុជា/ថៃ<br>អង្គការស្ម័គ្រចិត្តអន្តរជាតិអូស្ត្រាលី (AVI) | |